AFESIP
AGIR POUR LES FEMMES
EN SITUATION PRÉCAIRE

# របាយការណ៍ប្រចាំឆ្នាំ២០២០

## ស្តីអំពី

# ការប្រតិបត្តិសកម្មភាពការងារ
# អង្គការអា ហ្វេស៊ីប-កម្ពុជា

## ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២០


អ្នកធ្វើរបាយការណ៍: **លោក សៅ ឈឿត**
**នាយកកម្មវិធី**
E-mail: afesip.nc@gmail.com

## I.ការពិពណ៌នាអំពីអង្គការ

អង្គការ អាហ្វេស៊ីប កម្ពុជា បានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដោយ **លោកស្រី សុម៉ាលី ម៉ម** (លោកស្រីផ្ទាល់ជាជនរងគ្រោះដោយការជួញដូរ) ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ លើស្ត្រី និងកុមារ។ អង្គការ អាហ្វេស៊ីប កម្ពុជា ប្រយុទ្ធប្រឆាំង នូវគ្រប់ទំរង់ នៃការជួញដូរមនុស្ស និង វិធានការការពារ ក្នុងគោលបំណងកាត់បន្ថយ តម្រូវការជនរងគ្រោះដោយការជួញដូរមនុស្ស តាមរយៈការប្រយុទ្ធប្រឆាំង អំពើហឹង្សាលើស្ត្រី-កុមារី (វិសមភាពយែនឌ័រ) ព្រោះថាអំពើហឹង្សាលើស្ត្រី-កុមារី វាជាផ្នែកមួយនៃបញ្ហាសិទ្ធិមនុស្ស។

អង្គការ អាហ្វេស៊ីប កម្ពុជា ធ្វើការជួយដល់យុវនារី និងកុមាររងគ្រោះ ឬមានហានិភ័យខ្ពស់ក្នុងការងាយរងគ្រោះដោយអំពើជួញដូរផ្លូវភេទ ហឹង្សា រំលោភបំពាន រំលោភសេពសន្ថវៈ ទាសភាពជាប់កិច្ចសន្យា ឬកេងប្រវ័ញ្ច ដោយសហការជាមួយគ្រួសាររបស់ពួកគាត់ ក្នុងការផ្តល់សុវត្ថិភាព និង ការផ្តល់យុទ្ធសាស្ត្រអោយចាកចេញដោយនិរន្តភាព។

អង្គការ អាហ្វេស៊ីប កម្ពុជា ធ្វើការយ៉ាងជិតស្និតជាមួយមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងបណ្តាដៃគូរអន្តរជាតិនានា ដើម្បីផ្តល់តំណោះស្រាយសម្រួបចំពោះបញ្ហាពាក់ព័ន្ធ។

### ១.១ ចក្ខុវិស័យ

ជាពិភពលោកមួយដែលយុវនារី និង កុមារីមានសុវត្ថិភាពរួចផុតពីទាសភាព

### ១.២ ទិសដៅ

អង្គការ អាហ្វេស៊ីប កម្ពុជា ផ្តល់ការថែទាំ និងធានាបាននូវសិទ្ធិរបស់យុវនារី និង កុមារីរងគ្រោះ និងងាយរងគ្រោះដោយអំពើទាសភាព តាមរយៈការស្តារនីតិសម្បទា ការអប់រំ បណ្តុះបណ្តាល និងសមាហរណកម្មដោយជោគជ័យត្រឡប់ទៅសង្គមវិញ ដោយឯករាជ្យភាពហិរញ្ញវត្ថុ និរន្តភាព និងភាពថ្លៃប្រឌិត។ យើងអនុវត្តការងារនេះ ដោយជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនពួកគាត់ អំពីឯកភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពមុខរបរ។ បន្ទាប់មកយើងស្វាគមន៍លើកទឹកចិត្តអោយពួកគាត់ ក្លាយជាផ្នែកមួយរបស់បណ្តាញអតីតៈជនរងគ្រោះ ។

### ១.៣ ក្រុមគោលដៅ

ជាយុវនារី និង កុមារីជនរងគ្រោះ និងងាយរងគ្រោះ ដោយការជួញដូរ រំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទ។

### ១.៤ យុទ្ធសាស្ត្រ

ការប្រយុទ្ធប្រឆាំង អំពើជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទ លើយុវនារី និង កុមារី គឺជាកាតព្វកិច្ចដ៏ធំមួយដែលតម្រូវអោយមានពហុធនជាន។ យើងបានយកចិត្តទុកដាក់យ៉ាងខ្លាំង នូវតម្រូវការរបស់យុវនារី និង កុមារីនីមួយ ៗ ដែលយើងធ្វើការជាមួយ មកពិចារណាយ៉ាងហ្មត់ចត់ ដើម្បីផ្តល់ដំណោះស្រាយសម្រួបដល់ពួកគាត់ តាមរយៈកម្មវិធីសំខាន់ៗចំនួន៤ **(១) កម្មវិធីស្តារនីតិសម្បទា (២) កម្មវិធីអប់រំ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខាងក្រៅ (៣) កម្មវិធីក្រុមគោលដៅ (ការងារសង្គមសង្គ្រោះ) និង (៤) កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច (កម្មវិធីសមាហរណកម្ម)** ក្នុងការផ្លាស់ប្តូជីវិតជនរងគ្រោះ និង ជនងាយរងគ្រោះអោយក្លាយជាអតីតជនរងគ្រោះ និងត្រៀមទទួលយកការកែប្រែជីវិតថ្មី ដោយការទទួលខុសត្រូវ និងស្វ័យតម្លាភាព នូវជំនាញចាំបាច់ ដើម្បីអោយមាននិរន្តភាពសំរាប់ខ្លួនឯង និង គ្រួសារ។

ដើម្បីអោយមានតម្លាភាព ប្រសិទ្ធិភាពដល់យុវនារី និង កុមារីជាអ្នកទទួលផលពីកម្មវិធី ក៏ដូចជា ដើម្បីផ្តល់តម្លាភាព ជូនម្ចាស់ជំនួយ យើងមាននីតិវិធីជាក់លាក់ក្នុងការផ្តល់ជូនវឌ្ឍនភាពគំរោង ដែលអាចវាយតម្លៃពីការវិវឌ្ឍន៍ និងសមទ្ធិផលសំរេចបានរបស់គំរោង ដោយក្រុមការងាររបស់អង្គការ អាហ្វេស៊ីប កម្ពុជា បានដាក់ចេញនូវទិសដៅជាក់លាក់ដែលអាចវាស់វែងបាន អំពីសុច្ចនៈករដែលបានរំពឹងទុក និងផែនការណ៍សម្មភាពដែលអាចធ្វើបាន និងអាចវាស់វែង អាចបង្ហាញអំពីលទ្ធផលសំរេចបាន នៅចុងកម្មវិធីនៃការអនុវតគំរោងនីមួយៗ។

## II. **អន្តរកម្មវិធីគន្លឹះទាំង៤របស់អង្គការ**

ខាងក្រោមនេះជាកាពិពណ៌នា អំពីកម្មវិធីទាំងឡាយដែលជាការឆ្លើយតបទៅនិងចក្ខុវិស័យ និងទិសដៅចំបងៗ ដែលអង្គការ អាហ្វេស៊ីប កម្ពុជា កំពុងប្រតិបត្តិការសកម្មភាពការងាររបស់ខ្លួនដោយអនុលោមតាមយុទ្ធសាស្រ្តដែលមានស្រាប់។

## ២.១ កម្មវិធីស្តារនីតិសម្បទា

យើងផ្តោតលើសកម្មភាពការងារចំបង ៗ ចំនួន៤ គឺ **ការផ្តល់ជំរកសុវត្ថិភាព ការថែរក្សាសុខភាព ការគាំទ្រជំនួយផ្នែកចិត្តសាស្រ្ត និង ជំនួយផ្នែកនីតិកម្ម**។ ដំណាក់កាលដំបូងគឺយើងជួយអោយជនរងគ្រោះ ឬ ជនងាយរងគ្រោះមានលំនឹងផ្លូវចិត្ត ពីវិបត្តិដែលពួកគេជួបប្រទះ នៅមណ្ឌលស្តារនីតិសម្បទា ទុំឌី ដែលជាកន្លែងអោយពួកគាត់អាចទទួលបានជំរកសុវត្ថិភាព ជួបជាមួយវេជ្ជបណ្ឌិត (គ្រូពេទ្យ) បុគ្គលិកចិត្តសាស្រ្ត បុគ្គលិកគាំពារច្បាប់ និង បានទទួលនូវតម្រូវការចាំបាច់ផ្សេង ៗទៀត ជាច្រើនតាមតម្រូវការជាក់ស្តែងរបស់ពួកគាត់។

យើងទទួលស្គាល់ថាឥទ្ធិពល នៃការប៉ះដង្ហិចផ្នែកចិត្តសាស្រ្ត គឺបានកាត់ផ្តាច់អំណាចឥទ្ធិពល និង ការផ្សាភ្ជាប់ទំនាក់ទំនង ដូច្នេះវិធីសាស្រ្ត នៃការស្តារនីតិសម្បទា យើងផ្តោតការយកចិត្តទុកដាក់លើការកសាងអំណាចឥទ្ធិពលនិង ការបង្កើតទំនាក់ទំនងជាថ្មីឡើងវិញ ដល់យុវនារី-កុមារី ដែលយើងធ្វើការជាមួយ ទាំងនៅក្នុងមណ្ឌល និង តាមសហគមន៍។

បណ្តាញលើកកម្ពស់អតីតជនរងគ្រោះ ដើរតួយ៉ាងសំខាន់ ក្នុងការជួយដល់យុវនារី និង កុមារីចូលថ្មីនៅក្នុងមណ្ឌល ក្នុងការបង្កើតភាពជឿជាក់ និង ការកសាងទំនាក់ទំនងជាថ្មីជាមួយមនុស្សជុំវិញខ្លួនឡើងវិញ ។ កម្មវិធីជាច្រើនត្រូវបានបង្កើតឡើង ដោយអនុលោមតាមបទដ្ឋាន និងតាមដំណាក់កាលសំខាន់ៗ ដែលអាចបត់បែនបាន និង យកចិត្តទុកដាក់ខ្ពស់ដល់គ្រប់អតីតជនរងគ្រោះ នៅពេលពួកគាត់មកដល់មណ្ឌលថែទាំ ហើយយើងផ្តល់អាទិភាពទៅតាមតម្រូវការជាក់ស្តែងរបស់បុគ្គលនីមួយៗ ។

ជនរងគ្រោះទាំងឡាយណាដែលពាក់ព័ន្ធនិងនីតិវិធីច្បាប់ យើងផ្តល់ជំនួយផ្នែកច្បាប់តាមនីតិវិធី ដោយសហការជាមួយបណ្តាអង្គការដៃគូរផ្នែកច្បាប់ ដើម្បីជួយដល់ជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌ និងសំណងរដ្ឋប្បវេណីជូនជនរងគ្រោះ។ បុគ្គលិកផ្នែកច្បាប់របស់យើងធ្វើការជាមួយបណ្តាអង្គការដៃគូរ ដើម្បីរៀបចំករណីដែលពាក់ព័ន្ធផ្លូវច្បាប់ និងធានាអោយបានថា គ្រប់ជនរងគ្រោះដែលពាក់ព័ន្ធផ្លូវច្បាប់ ត្រូវទទួលបានជំនួយផ្នែកច្បាប់ និងការគាំពារតាមនីតិវិធីចំពោះមុខច្បាប់ នៅតុលាការ ។

## ២.២ កម្មវិធីអប់រំ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅខាងក្រៅ

បុគ្គលិកយើងធ្វើការវាយតម្លៃលើយុវនារី និងកុមារីនីមួយៗ ដោយយកចិត្តទុកនៅពេលពួកគាត់ចូលមកដល់មណ្ឌល ថាតើពួកគាត់ត្រូវរៀនចំណេះដឹងទូទៅ ឬ រៀនជំនាញវិជ្ជាជីវៈនៅខាងក្រៅ ។

ការអប់រំក្នុងប្រព័ន្ធយើងបែងចែកជា៣ប្រភេទមានជាអាទិ(១)**ការអប់រំចំណេះដឹងទូទៅនៅសាលារដ្ឋ/សាធារណៈ** ខណៈពេលកុមារីស្ថិតនៅក្រោមការថែរក្សានៅក្នុងមណ្ឌលស្តានីតិសម្បទា(២)**ការសិក្សាអប់រំនៅសហគមន៍** ត្រូវបានធ្វើឡើងនៅពេលកុមារីបានស្តារនីតិសម្បទារួចរាល់ហើយ ៗ បានធ្វើសមាហរណកម្មទៅក្រុមគ្រួសារវិញ នៅតាមសហគមន៍ហើយបន្តការសិក្សាចំណេះដឹងទូទៅ ខណៈពួកគេកំពុងរស់នៅជាមួយក្រុមគ្រួសារ និង (៣) **ការអប់រំនៅឧត្តមសិក្សា សំរាប់អាហារូបករណ៍នៅសកលវិទ្យាល័យ** ។ យើងធ្វើការតាមដាន ឃ្លុំមើល យ៉ាងទៀងទាត់បំផុតពីស្ថានភាពនៃការរស់នៅ ការសិក្សា និងការវិវឌ្ឍន៍ផ្សេងៗ របស់កុមារីទាំងនេះ ដោយយកចិត្តទុកដាក់ ។

**ការអប់រំចំណេះដឹងទូទៅពេលស្នាក់នៅក្នុងមណ្ឌល**-កម្មវិធីអប់រំក្នុងប្រព័ន្ធ ចាប់ផ្តើមឡើងនៅមណ្ឌលស្តារនីតិសម្បទាទុំឌី ដែលមានទិសដៅសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស អោយបញ្ចប់ការសិក្សាប្រកបដោយគុណភាព និងទំនុកចិត្ត ដែលអាចមានសមត្ថភាព ប្រកបអាជីពវិជ្ជាជីវៈ ជាគិលានុបដ្ឋាយិកា អ្នកចិត្តវិទ្យា គណនេយ្យ និងហិរញ្ញវត្ថុធុរកិច្ចនិងរដ្ឋបាល ការគ្រប់គ្រង នីតិកម្មនិងសេដ្ឋកិច្ច អក្សរសាស្ត្រអង់គ្លេស អក្សរសាស្ត្រខ្មែរ បដិសណ្ឋារកិច្ចនិងទេសចរណ៍ ព័ត៌មានវិទ្យា រដ្ឋបាលសាធារណៈ ទំនាក់ទំនងនិងទីផ្សារ ទីផ្សារនិងធនាគារ និងវិស័យផ្សេងៗ ទៀតនៅពេលពួកគាត់បញ្ចប់ការសិក្សា។

ចំពោះកុមាររងគ្រោះដែលគ្រប់អាយុចូលរៀននៅសាលាបឋមសិក្សា ទិសដៅសំខាន់របស់យើងគឺធានាអោយបានថាពួកគាត់ទទួលបានការសិក្សាអប់រំជាក់លាក់មួយ នៅក្នុងបរិយាកាសសាលាសាធារណៈប្រកបដោយសុវត្ថិភាព។ ប្រសិនបើកុមារជាកុមារកំព្រា ឬ មិនមានសុវត្ថិភាពគ្រប់គ្រាន់ក្នុងការរស់នៅផ្ទះ យើងផ្តល់ការសិក្សាអប់រំចំណេះទូទៅអោយពួកគាត់ នៅខណៈពេលពួកគាត់ស្នាក់នៅមណ្ឌលស្តារនីតិសម្បទា ទុំឌី នៅទីក្រុងភ្នំពេញ។ កុមារីនៅមណ្ឌលទុំឌីចូលរៀននៅសាលាសាធារណៈនៅក្បែរមណ្ឌល ដែលមានរយៈចម្ងាយអាចជិះកង់ទៅរៀនបាននៅសាលាបឋមសិក្សា យើងមានរថយន្តសំរាប់ដឹកជញ្ជូនកុមារីទៅរៀននៅសាលាមធ្យមសិក្សា និង វិទ្យាល័យដែលនៅឆ្ងាយពីមណ្ឌល។ យើងផ្តល់ថ្នាក់រៀនគួបន្ថែមនៅក្នុងមណ្ឌល ជាករណីចាំបាច់ដើម្បីអោយកុមារីរៀនទាន់កម្មវិធីនៅសាលារបស់ពួកគាត់។

**ការរៀនភាសាអង់គ្លេស កំព្យូទ័រ និង បណ្ណាល័យ**-យើងបង្រៀនភាសាអង់គ្លេស និង កំព្យូទ័រ ដល់កុមារីនៅក្នុងមណ្ឌល និង កុមារីមកពីគ្រួសារក្រីក្រ តាមសហគមន៍នៅក្បែរ ៗ មណ្ឌល ទុំឌី ៥ថ្ងៃក្នុង១សប្តាហ៍ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ បង្រៀន៥ម៉ោងក្នុង១ថ្ងៃ យើងបែងចែកកុមារជា៤ក្រុមរៀនភាសាអង់គ្លេស និង ៤ក្រុមទៀតរៀនកំព្យូទ័រ ។ ពួកគាត់អាចចូលអានសៀវភៅ និង ធនធានសិក្សា តាមមុខវិជ្ជាផ្សេង ៗ ជាច្រើននៅក្នុងបណ្ណាល័យនៅមណ្ឌល ទុំឌី។

**ការហ្វឹកហ្វឺនរបាំប្រពៃណីខ្មែរ យោគៈ និង សមាធិ** យើងបានរៀបចំសំរាប់កុមារីជារៀងរាល់ចុងសប្តាហ៍ និង ថ្ងៃសីល។

**ការសិក្សាអប់រំនៅសហគមន៍(CBE)**-យើងលើកកម្ពស់ការចិញ្ចឹមបីបាច់ថែរក្សាកុមារអោយរស់នៅក្នុងបរិយាកាសគ្រួសារជាជាងអោយពួកគាត់រស់នៅតាមគ្រឹះស្ថាន ដូច្នេះការធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ គឺជាជំរើសអាទិភាព តាមដែលអាចធ្វើទៅបាន ក្រោយពីយើងទទួលបានការបញ្ជាក់អំពីសុវត្ថិភាព និង សុខមាលភាពរបស់ពួកគាត់ ថាអាចសមារណកម្មបាន យើងឧបត្ថម្ភជាការសិក្សាអប់រំនៅសហគមន៍ ឬ បញ្ជូនទៅសិក្សាជំនាញវិជ្ជាជីវៈនៅខាងក្រៅ ។ ជាជំរើសដ៏ត្រឹមត្រូវបំផុតដែលកុមារីត្រូវបន្តការសិក្សាហើយរស់នៅផ្ទះជាមួយក្រុមគ្រួសារពួកគាត់ យើងឧបត្ថម្ភសម្ភារៈ

សិក្សា ឯកសណ្ឋានសិស្ស និង ថ្លៃរៀនគួបន្ថែម ដើម្បីអោយកុមារបានចូលរៀន និងការពារពួកគាត់កុំអោយបោះបង់ការសិក្សាដើម្បីទៅរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។

**ការអប់រំថ្នាក់ឧត្តមសិក្សានៅសកលវិទ្យាល័យ** (HEU)-កុមារីដែលបានប្រឡងបញ្ចប់ថ្នាក់ទី១២ (មធ្យមសិក្សាទុតិយភូមិ) មានសិទ្ធដាក់ពាក្យស្នើសុំអាហារូបករណ៍រៀនបន្តនៅសកលវិទ្យាល័យបាន ។ អង្គការ អាហ្វេស៊ីប កម្ពុជា ជឿជាក់យ៉ាងមុតមាំថា នេះជាពេលវេលាដ៏សំខាន់ ក្នុងការផ្តល់ឳកាសអោយកុមារីបានបន្តការសិក្សា។ យើងមានផែនការណែនាំអំពីកម្មវិធីជួយដល់ពួកគេដែលបណ្តាអង្គការឬសាធារណៈជន អាចចូលរួមជួយឧបត្ថម្ភគាំទ្រនូវតម្លៃសិក្សារបស់អតីតជនរងគ្រោះ (កុមារី) ណាម្នាក់ ដូចជាជួយឧបត្ថម្ភថ្លៃសិក្សា ការចាយវាយផ្សេងៗ និងការជួយលើមុខវិជ្ជាសិក្សាជាក់លាក់ណាមួយរបស់កុមារី។ យើងរំពឹងថា និស្សិតនឹងតបស្នងមកអង្គការវិញ តាមរយៈផ្តល់ការហ្វឹកហ្វឺនការងារក្រោយពេលពួកគេបញ្ចប់ការសិក្សា ដែលអាចជាការផ្តល់ផលប្រយោជន៍បន្ថែម ក្នុងការជំរុញការទទួលខុសត្រូវ និងការលើកកម្ពស់និរន្តភាពសេដ្ឋកិច្ចរយៈពេលវែង។

ទិសដៅសំខាន់របស់យើងគឺលើកទឹកចិត្តជនរងគ្រោះ អោយក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះ អោយក្លាយជាផ្នែកមួយនៃដំណោះស្រាយ ។ បច្ចុប្បន្ន យើងមានអតីតជនរងគ្រោះដែលបានបញ្ចប់ការសិក្សាពីសកលវិទ្យាល័យកំពុងបំរើការក្នុង អង្គការ អាហ្វេស៊ីប កម្ពុជា ដូចជាប្រធានមណ្ឌល កម្មវិធីចិត្តសាស្ត្រ កម្មវិធីក្រុមគោលដៅ កម្មវិធីសុខភាព កម្មវិធីអប់រំនិងបណ្តុះបណ្តាល ការិល័យរដ្ឋបាលនិងគណនេយ្យ កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច និងជាបុគ្គលិថែរទាំ ជាដើម។

**ការបណ្តុះបណ្តាលជំនាញខាងក្រៅ (OST)**-អតីតជនរងគ្រោះដែលមានអាយុច្រើនជាទូទៅចាប់ពី១៦ឆ្នាំឡើងទៅ តែងតែចង់រៀនជំនាញវិជ្ជាជីវៈអោយបានចប់ឆាប់ ៗ តាមតែអាចធ្វើទៅបាន ជាប្រយោជន៍ ដើម្បីអោយពួកគេអាចវិលត្រឡប់ទៅចាប់ផ្តើមការរស់នៅដោយស្វ័យនិរន្តភាព ឬ ជាមួយក្រុមគ្រួសារវិញ ។ ចំណុចសំខាន់នៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ គឺជាប្រភាពចំណូលស្វ័យទ្រទ្រង់ និង ជាបំណិនជីវិតចាំបាច់សំរាប់យុវនារីម្នាក់ ៗ ក្នុងការជួយទ្រទ្រង់ខ្លួនគាត់ និង ក្រុមគ្រួសាររបស់គាត់អោយមានស្ថេរភាព និង ឯករាជ្យភាព ។

យើងផ្តោតសំខាន់លើសារប្រយោជន៍បំណិនជីវិត និង ការបណ្តុះបណ្តាលអំពីរបៀបបង្កើតមុខរបរតាមរយៈ ភាពជាដៃគូរ ជាមួយបណ្តាអ្នកឯកទេស ដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និង បណ្តាអង្គការក្រៅរដ្ឋាភិបាលនានា ជាជាងការផ្តល់ការបណ្តុះបណ្តាលផ្ទាល់នៅក្នុងអង្គការ អាហ្វេស៊ីប កម្ពុជា ។ មកដល់ពេលនេះ យើងបានប្រមូលចងក្រងឯកសាររាយបញ្ជីមុខជំនាញវិជ្ជាជីវៈផ្សេងៗ បានជាង៣០មុខវិជ្ជា (បញ្ជីរាយមុខជំនាញវិជ្ជាជីវៈបណ្តុះបណ្តាលខាងក្រៅ) ដូចជាជំនាញអ៊ុតសក់ កាត់ដេរ ធ្វើនំ ភោជនីយដ្ឋាន បដិសណ្ឋារកិច្ច ។ល។ ទិសដៅសំខាន់បំផុត គឺជួយអោយពួកគាត់មានលទ្ធភាពសំរេចបានឯករាជ្យភាពសេដ្ឋកិច្ច និង សេចក្តីថ្លៃថ្នូរនៅពេលពួកគាត់ត្រឡប់ទៅសហគមន៍វិញ។ យន្តការទាំងនេះ គឺបើម្បីពន្លឿននីតិវិធី បង្កលទ្ធភាពអាចធ្វើសមាហរណកម្មយុវនារី និង កុមារីនីមួយ ៗ បានលឿន តាមដែលអាចធ្វើទៅបាន ។

## ២.៣ កម្មវិធីលើកកំពស់សេដ្ឋកិច្ច (EEP) (កម្មវិធីសមាហរណកម្ម)

យុវនារី ឬ កុមារី ដែលមានវឌ្ឍនភាពលើការស្តារនីតិសម្បទា ការអប់រំ និង បណ្តុះបណ្តាល យើងអាចចាប់ផ្តើមនីតិវិធីធ្វើសមាហរណកម្មពួកគាត់ត្រឡប់ទៅកាន់ជីវិតធម្មតាវិញ។ នីតិវិធីនេះពាក់ព័ន្ធនិងការធ្វើជាកូនជាង ឬ ជាអ្នក

ហ្វឹកហ្វឺនការងារនៅកន្លែងណាមួយ ។ ពួកគេរៀនរស់នៅដោយម្ចាស់ការលើខ្លួនឯង (ឯករាជ្យ) គ្រប់គ្រង ចាត់ចែងការចាយវាយលុយកាក់ផ្ទាល់ខ្លួន និង ធានាអោយបានថា ពួកគាត់អាចចូលរួមចំណែកបានដោយប្រក្រតីក្នុងការប្រើប្រាស់អាជីពដែលពួកគាត់បានជ្រើសរើស។

សមាហរណកម្ម ជាការងារដែលពាក់ព័ន្ធ ការស្រាវជ្រាវស្វែងរកក្រុមគ្រួសារ ការទៅលេងគ្រួសារ ការសិក្សាវាយតំលៃស្ថានភាពគ្រួសារ និង ឯកភាពវប្បនីយកម្ម (ការសំរុះសំរួល) ការសិក្សាវាយតំលៃសហគមន៍ ការជួយគាំទ្រសកម្មភាពរកប្រាក់ចំណូលផ្សេង ៗ សំរាប់គ្រួសាររបស់យុវនារីនិងកុមារី ការធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសកំណើតវិញតាមតម្រូវការជាក់ស្តែង និង ការតាំងទីលំនៅដោយឯករាជ្យនៅតាមសហគមន៍។

ចំពោះយុវនារី ដែលបានប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិ នេះជាពេលដែលត្រូវចាប់ផ្តើមអាជីពរបស់ពួកគាត់ ឬ ត្រូវរៀនបន្តនៅសកលវិទ្យាល័យ ។ អន្តរកាលរបស់ពួកគាត់នេះគឺមានសារៈសំខាន់ណាស់ តម្រូវអោយមានការគ្រប់គ្រងដោយប្រុងប្រយ័ត្ន ដើម្បីធានាអោយបានថាពួកគាត់អាចរស់បានដោយមាននិរន្តភាពលើជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់។

ដើម្បីធានាអោយបាន នូវការបន្តភាពជោគជ័យរបស់អតីតជនរងគ្រោះ ដែលបានស្តារនីតិសម្បទា និង រៀនចប់កម្មវិធីផ្សេង ៗ តម្រូវអោយបុគ្គលិកកម្មវិធីលើកកំពស់សេដ្ឋកិច្ច ធ្វើការតាមដានបន្តទៅលើអតីតជនរងគ្រោះ ក្រោយពីការធ្វើសមាហរណកម្មរួចហើយ សំរាប់រយៈពេលមួយដោយគ្មានកំណត់ តាមស្ថានភាពជាក់ស្តែងរបស់ករណីនីមួយ ៗ ។ បុគ្គលិកតាមដានបន្តពីភាពជោគជ័យរបស់កម្មវិធី ដោយការធ្វើរបាយការណ៍អំពីប្រភពចំណូល-ចំណាយរបស់យុវនារី និង អំពីស្ថានភាពផ្សេង ៗ របស់ពួកគាត់ (ឧ. ហានិភ័យ ឱនភាព និរន្តរភាព និង ភាពជោគជ័យ)។

ប្រហាក់ប្រហែលគ្នានិងកម្មវិធីជួយឧបត្ថម្ភថ្លៃសិក្សាសំរាប់អតីតជនរងគ្រោះណាម្នាក់នៅឧត្តមសិក្សាដែលយើងបានបរិយាយខាងលើ យើងស្វែងរកមូលនិធិដើម្បីជួយផ្តល់ឱកាសដល់យុវនារី ដែលចង់ធ្វើការនៅកន្លែងអង្គការណាមួយដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ បានធ្វើការជាមួយនិយោជកល្អត្រឹមត្រូវ និង មានសុវត្ថិភាព គឺជួយដល់យុវនារីដែលបានបញ្ចប់ការសិក្សាអោយទទួលបានឱកាសល្អ ដើម្បីអភិវឌ្ឍន៍វិជ្ជាជីវៈរបស់ខ្លួនអោយទទួលបានជោគជ័យ។

យើងបានចងក្រងក្រុមការងារ ដោយធ្វើការជាមួយបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ/សម្លេងដើម្បីផ្លាស់ផ្តូរ (Voices For Changers (VFC) ដើម្បីជួយដល់អតីតជនរងគ្រោះអោយទទួលបានសក្តានុពលខ្ពស់ឆ្ពោះទៅរកភាពជោគជ័យ ទោះបីជាគាត់ចាប់ផ្តើមមុខរបរផ្ទាល់ខ្លួន ឬ បំរើការអោយគេក៏ដោយ។ ជាការពិត យើងមិនបានផ្តល់ការអប់រំ និង បណ្តុះបណ្តាលអោយពួកគាត់បានគ្រប់គ្រាន់នោះទេ ដូច្នេះសមាជិកបណ្តាញក្រុមសម្លេងដើម្បីផ្លាស់ផ្តូរ ធ្វើការជាមួយយុវនារីនីមួយ ៗ ដែលបានបញ្ចប់ការសិក្សា ដើម្បីធានាអោយទទួលបានលទ្ធផលល្អប្រសើរនាពេលអនាគត។

**ការតាមដានបន្តក្រោយពេលធ្វើសមារណកម្ម**-ការតាមដានបន្តយុវនារី និង កុមារី ដែលបានសមាហរណកម្មរួចហើយ គឺមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការផ្តល់ការគាំទ្រ ផ្តល់ជំបូន្មាន ដើម្បីអោយការធ្វើសមាហរណកម្មទទួលបានជោគជ័យ ផ្តល់ការឧបត្ថម្ភបន្ថែមតាមតម្រូវការជាក់ស្តែង ចុះសួរសុខទុក្ខ ពិនិត្យតាមដានបន្ត អំពីស្ថានភាពផ្សេងៗ ។

គោលដៅសំខាន់ គឺជួយអោយយុនារីនីមួយ ៗ សំរេចបានស្វ័យឯករាជ្យ ព្រោះដំណាក់កាលនេះយុវនារី ដែលបានទទួលផលពីកម្មវិធី មិនពឹងផ្អែកលើការជួយជ្រោមជ្រែងពីអង្គការទៀតនោះទេ ព្រោះពួកគាត់អាចមានលទ្ធភាពជួយសង្គមវិញតាមរយៈការជួយយុវនារីដ៏ទៃទៀត ដែលកំពុងត្រៀមខ្លួនឆ្ពោះមកកាន់ដំណាក់កាលនេះដែរ ។ យើងបានបង្រៀនពួក

គាត់ អំពីសារៈសំខាន់ នៃគណនេយ្យភាព និង ទំនួលខុសត្រូវរបស់បុគ្គលម្នាក់ ៗ ក្នុងអំឡុងពេលដែលពួកគាត់ស្នាក់នៅ អាហ្វេស៊ីបកម្ពុជា ដូច្នេះពួកគាត់រីករាយក្នុងការជួយមកអង្គការវិញ ។ ការជួយមកអង្គការវិញ អាចក្នុងរូបភាពជាការជួយ ដល់អតីតជនរងគ្រោះដ៏ទៃទៀត នៅខណៈពេលពួកគាត់ចាប់ផ្តើមបង្កើតមុខរបរថ្មី ឬ ជាតម្លៃសម្ភារៈសំរាប់បង្កើតមុខ របរដែលជាផ្នែកមួយនៃពិធីសមាហរណកម្មយើងត្រូវផ្តល់ជូនគាត់ និងចូលជាសមាជិករបស់បណ្តាញអតីតជនរង គ្រោះសំលេងដើម្បីផ្លាស់ប្តូរ VFC ។

បុគ្គលិកក្រុមការងារធ្វើការជាមួយយុវនារី ដើម្បីធានាអោយបានថាយុវនារី ដែលបានបញ្ចប់ការសិក្សា បានរៀនអំពីតម្លៃ ស្វ័យវិនិយោគ (វិនិយោគលើខ្លួនឯង) និង គុណតម្លៃនៃការចែករំលែកតាមរយៈការជួយសង្គមវិញ ជាដំបូងត្រូវធ្វើអោយ ជីវិតខ្លួនឯងមានលំនឹងជាមុនសិន ដោយបុគ្គលិកក្រុមការងារយើងជួយអោយពួកគាត់ទទួលបានភាពជោគជ័យ និង ធ្វើ អោយប្រសើរឡើង នូវស្ថានភាពសេដ្ឋកិច្ចរបស់ពួកគាត់ដែលរស់នៅតាមសហគមន៍។ ការជួយរបស់ពួកគាត់អោយ ទទួលបានជោគជ័យ គឺការជួយដល់យុវនារីដ៏ទៃទៀត ដែលកំពុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មវិធីនៅឡើយ និង ធ្វើការតស៊ូមតិសំរាប់យុវនារី និង កុមារីដ៏ទៃទៀត។

យើងតែងតែប្រារព្ធធ្វើសិក្ខាសាលាប្រចាំឆ្នាំ ស្តីពីការចែករំលែក និង ការឆ្លុះបញ្ចាំង យ៉ាងហោចណាស់មួយឆ្នាំម្តង ជាមួយអតីតជនរងគ្រោះ ដែលកំពុងស្នាក់នៅក្នុងមណ្ឌលត្រៀមធ្វើសមាហរណកម្ម និងអតីតជនរងគ្រោះដែលបានធ្វើ សមាហរណកម្មរួចហើយ ក្នុងគោលបំណងចែករំលែកបទពិសោធន៍ អំពីភាពជោគជ័យនៃការកសាងជីវិតថ្មីក្នុងសង្គម។

## ២.៤ កម្មវិធីក្រុមគោលដៅ (កម្មិធីសង្គមសង្គ្រោះ)

បុគ្គលិកកម្មវិធីក្រុមគោលដៅ ចុះទៅផ្តល់ការអប់រំ នៅតាមទីតាំងកំសាន្តសប្បាយនានា (វិស័យ/ឧស្សាហកម្ម ផ្លូវភេទ) ដូចជា ហាងម៉ាស្សា ការ៉ាអូខេ ហាងលក់ស្រាបៀរ ភោជនីយដ្ឋាន ផ្ទះដួល និង តាមសួនច្បារសាធារណៈ ជាដើម ដើម្បីចែកស្រោមអនាម័យ និង សម្ភារៈអនាម័យផ្សេង ៗ ដោយឥតគិតថ្លៃ ដល់ស្ត្រីបំរើសេវាកំសាន្តសប្បាយ ជាការលើក ទឹកចិត្តដល់ពួកគាត់ដែលបានចូលរួមជាមួយកម្មយើង និង ដើម្បីលើកកម្ពស់ការរួមភេទដោយសុវត្ថិភាព។

ការបញ្ជ្រាបការយល់ដឹង អំពី ហ៊ីវ/អេដស៍ ជម្ងឺកាមរោគ ការប្រើប្រាសសារធាតុញៀន អនាម័យខ្លួនប្រាណ សិទ្ធិមនុស្ស និង ស្វ័យការពារ យើងបានផ្តល់វគ្គបណ្តុះបណ្តាលដល់ស្ត្រីបំរើសេវាកំសាន្តសប្បាយ ដែលបានចូលរួមជាមួយកម្មវិធី ក្រុមគោលដៅរបស់យើង នេះជាស្ពាន ក្នុងការផ្សារភ្ជាប់ កសាងទំនុកចិត្តរវាងស្ត្រីបំរើសេវាកំសាន្តសប្បាយ និង អង្គការ អាហ្វេស៊ីប កម្ពុជា។ បុគ្គលិកយើងបានធ្វើការសម្របសម្រួលជាមួយដៃគូរ ដើម្បីបញ្ជូនស្ត្រីបំរើសេវាកំសាន្តទាំងឡាយ ណាដែលបញ្ហាសុខភាព ទៅកាន់មន្ទីរពេទ្យ ឬ គ្លីនិកសុខភាព ដែលអង្គការ អាហ្វេស៊ីប កម្ពុជា សហការជាមួយ ដើម្បីអោ យពួកគាត់បានទទួលសេវាកម្មថែទាំសុខភាពតាមតម្រូវការ។ ក្រៅអំពីការបញ្ជ្រាបការយល់ដឹង បុគ្គលិកកម្មវិធីនេះ បានដើរតួនាទីយ៉ាងសំខាន់មួយផ្សេងទៀត គឺការបញ្ចុះបញ្ចូលដល់ស្ត្រីបំរើសេវាកំសាន្តសប្បាយអោយលះបង់មុខរបរ បច្ចុប្បន្នរបស់ខ្លួន និង ប្រមូលពត៌មានអំពីករណីជួញដូរមនុស្ស ក្នុងគោលបំណងជួយសង្គ្រោះជនរងគ្រោះ។

# III. សុច្ចនៈកររំពឹងទុក និង លទ្ធផលសំរេចបាន

## ៣.១ របាយការណ៍សង្ខេប

ការធ្វើការជាមួយជនរងគ្រោះ ដោយអំពើហឹង្សាផ្លូវភេទ ជួញដូរ រំលោភបំពាន ទាសភាពជាប់កិច្ចសន្យា ឬ ការ កេងប្រវ័ញ្ចផ្លូវភេទ គឺមានការស្មុគស្មាញខ្លាំងណាស់ ដែលតម្រូវអោយអង្គការ អាហ្វេស៊ីប កម្ពុជា ធ្វើការជាអន្តរកម្មវិធី

ដើម្បីផ្តល់សេវាកម្មជនរងគ្រោះ ដល់ជនរងគ្រោះតាមតម្រូវការចាំបាច់ និង តាមឆន្ទៈរបស់ពួកគាត់ ដោយការចាប់ផ្តើមពីការកំណត់អត្តសញ្ញាណជនរងគ្រោះ រហូតដល់ការធ្វើសមាហរណកម្មអតីតជនរងគ្រោះទៅកាន់សហគមន៍វិញ។ ស្ថាបនិក និង នាយិកាយើង លោកស្រី **សុម៉ាលី ម៉ម** បានមានប្រសាសន៍ថា *“ យើងចំណាយពេល៥នាទីសង្គ្រោះកុមារីម្នាក់ ប៉ុន្តែ យើងត្រូវការពេលវេលារាប់ឆ្នាំ ដើម្បីស្តារនីតិសម្បទាកុមារម្នាក់ អោយជាសះស្បើយពីរបួសផ្លូវកាយ និង របួសផ្លូវចិត្តដែលកុមារបានឆ្លងកាត់ ”*។

នេះជាការអនុវត្តបន្តនូវសកម្មភាពកម្មវិធីដែលមានស្រាប់ ដូច្នេះរបាយការណ៍ប្រចាំឆ្នាំ២០២០នេះ យើងផ្តោតតែលើសកម្មភាពកម្មវិធីដែលសម្រេចបាន ប្រៀបធៀបជាមួយសុច្ចនៈករណ៍ពឹងទុក ដែលយើងបានចងក្រងនៅក្នុងផែនការមេ ដែលប្រធានកម្មវិធីនីមួយ ៗ បានធ្វើបទបង្ហាញនៅចុងឆ្នាំ២០១៩ និង បានទទួលការអនុម័ត ឯកភាពពីក្រុមប្រឹក្សាភិបាលប្រតិបត្តិរបស់អង្គការ អាហ្វេស៊ីប កម្ពុជា។

លទ្ធផលសំរេចបាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំនេះ គឺជាលទ្ធផលនៃការអនុវត្តរួម ចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ បានទទួលការឧបត្ថម្ភហិរញ្ញវត្ថុ ពីបណ្តាម្ចាស់មូលនិធិ និង អ្នកគាំទ្រដែលបានឧបត្ថម្ភដល់កម្មវិធីផ្សេង ៗ តាមទិសដៅរបស់ខ្លួន ប៉ុន្តែជាវិភាគទានរួមដែលនាំអោយសំរេចបាននូវលទ្ធផលរួមនៃបណ្តាកម្មវិធីរបស់អង្គការអាហ្វេស៊ីបកម្ពុជាទាំងអស់សំរាប់រយៈពេល១២ខែ។

## អ្នកទទួលផលគំរោង

យើងអនុវត្តសកម្មភាពការងារ ដោយអនុលោមទៅតាមគោលដៅ និង ទិសដៅទាំងឡាយ ដែលបានដាក់ចេញ ហើយស្ទើរតែគ្រប់ផែនការសកម្មភាពទាំងអស់ យើងសំរេចបានលទ្ធផលល្អ តាមសុច្ចនៈករដែលបានរំពឹងទុក នៃសមិទ្ធិផលកម្មវិធីគន្លឹះទាំង៤ យើងមានបរិយាយនៅទំព័រទី១១ និង ១៣ខាងក្រោម។

ការងាររបស់យើង គឺសង្គ្រោះជីវិតមនុស្ស និង កសាងអនាគតអោយល្អប្រសើរសំរាប់យុវនារី និង កុមារីដែលយើងធ្វើការជាមួយ។ នៅឆ្នាំ២០២០ មានយុវនារី និង កុមារី ចំនួន៣៥២នាក់ បានទទួលសេវាកម្ម និង ការថែទាំពីអង្គការ អាហ្វេស៊ីប កម្ពុជា ដូចបានបង្ហាញជូនក្នុតារាងខាងក្រោមនេះ។ ស្ថិតិនេះមិនបានរាប់បញ្ចូលចំនួនស្ត្រីបំរើសេវាកំសាន្តសប្បាយ ដែលបានទទួលសេវាកម្មពីកម្មវិធីក្រុមគោលដៅរបស់អង្គការ អាហ្វេស៊ីប កម្ពុជាទេ ដូចបានបង្ហាញជូននៅផ្នែកកម្មវិធីក្រុមគោលដៅ ទ្រង់ចំណុច៣.២.៤ ទំព័រទី៣០ដល់៣១។

| ស្ថិតិកុមារីបានទទួលសេវាកម្មនៅឆ្នាំ២០២០ | | | | ស្ថិតិកុមារីដែលបានការចាកចេញ និង បន្តទទួលការថែទាំ | |
|---|---|---|---|---|---|
| ការពិពណ៌នា | សល់ពីឆ្នាំ២០១៩ | ចូលថ្មី២០២០ | សរុប | ចាកចេញនៅឆ្នាំ២០២០ | ទទួលការថែទាំបន្តសំរាប់ឆ្នាំ២០២១ |
| ទទួលការថែទាំក្នុងមណ្ឌល | ៦៤ | ២៣(២នាក់ចូលលើកទី២) | **៨៧** | ២៤ | ៦៣ |
| ទទួលការអប់រំក្នុងប្រព័ន្ធនៅមណ្ឌល | ៥៤ | ១២ | **៦៦** | ១៩(២នាក់មិនបានសិក្សានៅម.ណទេ) | ៤៧ |
| ទទួលជំនាញបណ្តុះបណ្តាលខាងក្រៅ | ២ | ៤ | **៦** | ២(២នាក់បានបញ្ចប់ការសិក្សា) | ៤ |
| ទទួលការសិក្សាអប់រំនៅសហគមន៍ | ៤៤ | ១៩ | **៦៣** | ៩* | ៥៤ |
| អាហារូបករណ៍សិក្សានៅសកលវិទ្យាល័យ | ១១ | ០ (មិនមានថ្មីលើកថ្ងៃប្រឡង) | **១១** | ២(១បណ្តេញចេញ១បោះបង់ការសិក្សា) | ១៥(៣ចូលខែមករានិង៣ទៀតចូលខែវិច្ឆិកា២០២១) |
| សមាហរណកម្មឧបត្ថម្ភមុខរបរ និ ងការងារ | ០ | ៤ | **៤** | ០ | ០ |
| ករណីសមាហរណកម្មដាមតានបន្ត | ១១៩ | ៦(២នាក់បញ្ជូនទៅគ្រួសារ) | **១២៥** | ០ | ១២៥+ |
| **សរុប** | **២៨១** | **៧១** | **៣៥២** | **៥៦** | **៣០៨** |

១៣*: យុវនារី២នាក់បានប្តូរទៅហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ កុមារី២នាក់បានទទួលចូលមណ្ឌលវិញដោយស្ថានភាពហានិភ័យខ្ពស់ក្នុងគ្រួសារ រីឯកុមារីចំនួន៥នាក់ទៀតបានបោះបង់ការសិក្សាដោយហេតុផលរៀបអាពាហ៍ពិពាហ៍ និងចេញទៅធ្វើការដើម្បីរកចំណូលជួយក្រុមគ្រួសារ។ល។

**អំពីបុគ្គលិក និង ការគ្រប់គ្រងគំពេង**

យើងមានបុគ្គលិកសរុបចំនួន៣១នាក់បានបំរើការនៅអង្គការ អាហ្វេស៊ីប កម្ពុជា នៅក្នុងឆ្នាំ២០២០។ បុគ្គលិក៣នាក់បំរើការនៅហាងអ៊ុតសក់+សម្រស់វិមាន នៅក្រុងសៀមរាប បុគ្គលិកធ្វើការមិនពេញម៉ោង២នាក់ (១នាក់ជាគ្រូពេទ្យ (វេជ្ជបណ្ឌិត) និង ១នាក់ទៀតជាបុគ្គលិកផ្នែកព័ត៌មានវិទ្យា/ស្ថិតិ) ២២នាក់ជាបុគ្គលិកប្រតិបត្តិការកម្មវិធី និង ៤នាក់ទៀតជាបុគ្គលិកគាំទ្រកម្មវិធី រួមមាន នាយិការគ្រប់គ្រង (Managing Director (MD) ១រូប នាយិការប្រតិបត្តិការ (Operation Director (OD) ១រូប នាយកកម្មវិធី (Program Director (PD) ១រូប និង រដ្ឋបាល និង គណនេយ្យ (Admin and accounting) ១រូប) ។

គោលដៅសំខាន់របស់យើង គឺជួយលើកទឹកចិត្តជនរងគ្រោះ អោយទៅជាអតីតជនរងគ្រោះ និង ជួយលើកទឹកចិត្តអតីតជនរងគ្រោះ អោយក្លាយទៅជាផ្នែកមួយ នៃដំណោះស្រាយ។ ក្នុងន័យនេះយើងបានដាក់ចេញនូវចក្ខុវិស័យដាក់លាក់មួយក្នុងរយៈពេល១០ឆ្នាំខាងមុខ ចាប់ពីឆ្នាំ២០១៨-២០២៨ បុគ្គលិក៩០%គឺជាអតីតជនរងគ្រោះ។ បច្ចុប្បន្ន យើងមានបុគ្គលិកចំនួន៩នាក់ (២៦%) នៃចំនួនបុគ្គលិកទាំង៣១នាក់ ជាអតីតជនរងគ្រោះ កំពុងបំរើការនៅតាមកម្មវិធីផ្សេង ៗ ដូចជា កម្មវិធីថែទាំសុខភាព ចិត្តសាស្រ្ត អប់រំនិងបណ្តុះបណ្តាល ការិល័យរដ្ឋបាលនិងគណនេយ្យ ក្រុមគោលដៅ ស្តារនីតិសម្បទា និង ហាងអ៊ុតសក់វិមាន។

យើងបានរៀបចំប្រជុំប្រចាំសប្តាហ៍ និង ប្រចាំខែយ៉ាងទៀងទាត់ ជាមួយបុគ្គលិកប្រតិបត្តិការកម្មវិធីទាំងអស់ នៅមណ្ឌលទុំឌី ក្នុងគោលបំណងចែករំលែករបាយណ៏របស់កម្មវិធីនីមួយ ៗ ទទួលយកការឆ្លើយតបនូវការតាមដានសកម្មភាព ពីអង្គប្រជុំពេលមុន ៗ ទទួលយកវឌ្ឍនភាពថ្មី បង្កើតឧបករណ៍ ឬ ក្រុមការងារតាមតម្រូវការជាក់ស្តែង និងដាក់ចេញផែនការសកម្មភាពដែលត្រូវធ្វើបន្តទៀត ។ល។ ការប្រជុំជាផ្នែកមួយនៃការជំរុញវឌ្ឍនភាព ការកសាងស្មារតីការងារជាក្រុម កសាងសមត្ថភាពបុគ្គលិក និង ការគ្រប់គ្រង តាមស្ថានភាព និង ការអនុវត្តជាក់ស្តែង។

ជារៀងរាល់ខែ ប្រធានកម្មវិធីនីមួយ ៗ ត្រូវធ្វើផែនការសកម្មភាព និង គំរោងថវិកា សំរាប់ការអនុវត្តសកម្មភាពកម្មវិធីរបស់ខ្លួន ដាក់ជូនប្រធានខ្សែបណ្តោយតាមរយៈសារអេឡិចត្រូនិកអ៊ីម៉ែល ដើម្បីពិនិត្យសំរេចជារៀងរាល់ថ្ងៃទី២៥នៃខែនីមួយ ៗ និង ត្រូវធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែដាក់ជូនប្រធានខ្សែបណ្តោយជារៀងរាល់សប្តាហ៍ទី១ នៃខែបន្ទាប់។ ជារៀងរាល់សប្តាហ៍ទី៤ នៃខែនីមួយ ៗ បុគ្គលិករបស់កម្មវិធី នីមួយ ៗ ត្រូវកត់ត្រាទិន្នន័យ ឬ កំណត់ហេតុការងារ របស់ខ្លួនចូលក្នុងសៀវភៅឯកសារ (paper file) ដើម្បីបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកំព្យូទ័រ សំរាប់ធ្វើរបាយការណ៏ផ្ទៃក្នុង (internal) និង របាយការណ៍ធ្វើចេញក្រៅ (external) តាមតម្រូវការជាក់ស្តែង។ បុគ្គលិកផ្នែកតាមដានការសិក្សាអប់រំរបស់យើង ជាអ្នកបញ្ចូលទិន្នន័យដែលបានកត់ត្រានៅលើសៀវភៅឯកសារទាំងអស់ ចូលទៅក្នុងប្រព័ន្ធទិន្នន័យកំព្យូទ័ររបស់កម្មវិធីនីមួយ ៗ ហើយប្រធានផ្នែកព័ត៌មានវិទ្យា/ទិន្នន័យ ជាអ្នកត្រួតពិនិត្យ និង កែតម្រូវរាល់ទិន្នន័យតាមផ្ទៃដែលមានកំហុសឆ្គង។

យើងបានរៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំ ស្តីពីលទ្ធផលសំរេចបានរបស់កម្មវិធីនីមួយ ៗ ប្រចាំឆ្នាំ ២០២០ និង លើកទិសដៅផែនការណ៍សកម្មភាពសំរាប់ឆ្នាំ២០២១ របស់កម្មវិធីនីមួយ ៗ នៅមណ្ឌលទុំឌី នាទីក្រុងភ្នំពេញ ពីថ្ងៃទី២៣-២៥ ខែខែវិច្ឆិកា ឆ្នាំ២០២០។ សកម្មភាពផ្តោតលើទិសដៅអង្គសិក្ខាសាលា មតិបើក និងបិទអង្គសិក្ខាសាលាថ្លែងដោយលោកស្រីសុម៉ាលី ម៉ម ជាស្ថាបនិក និងនាយិកាគ្រប់គ្រងអង្គការអាហ្វេស៊ីបកម្ពុជា ការរំពឹងទុកពីសិក្ខាសាលារបស់សិក្ខាកាម បទបង្ហាញរបស់កម្មវិធីនីមួយ ៗ ស្តីពីលទ្ធផលកម្មវិធីសំរេចបាន បញ្ហាប្រឈម អភិវឌ្ឍន៍

យុទ្ធសាស្ត្រថ្មីៗ បង្កើតផែនការសកម្មភាពសំរាប់ឆ្នាំ២០២១ ការគ្រប់គ្រងគំរោង និងការលើកទឹកចិត្តបុគ្គលិក បទបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ដោយសង្ខេប ការព្យាករប្រេកពហិរញ្ញវត្ថុ និងគំរោងថវិកាឆ្នាំ២០២១ និងការវាយតម្លៃកម្មវិធីពីសំណាក់អ្នកទទួលផលពីកម្មវិធី។

នៅក្នុងសិក្ខាសាលាយើងបានឯកភាពគ្នាជាឯកឆន្ទស្តីពីការគ្រប់គ្រងគំរោង ដោយការបិទកម្មវិធីក្រុមគោលដៅនៅឆ្នាំ២០២១ ដោយសារបញ្ហាថវិកា។ ជាក់ស្តែង យើងបានបិទកម្មវិធីនេះតាំងពីមានការផ្ទុះឡើងនូវវីរុសកូវីដ-១៩នៅក្នុងប្រទេសកម្ពុជានៅដើមខែមិនាឆ្នាំ២០២០មកម្លេះ ហើយយើងបានបញ្ចូលបុគ្គលិករបស់កម្មវិធី ទៅធ្វើការនៅតាមកម្មវិធីផ្សេង ៗ ដូចជា កម្មវិធីស្តារនីតិសម្បទា និងកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច(សមាហរណកម្ម)ជាដើម ហើយយើងបានឯកភាពគ្នាបង្កើតកម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះមកជំនួសកម្មវិធីក្រុមគោលដៅវិញ។ ដូច្នេះ អង្គការអាហ្វេស៊ីបកម្ពុជា នៅតែបន្តប្រតិបត្តិការកម្មវិធីស្នូលសំខាន់ ៗ ចំនួន៤ដដែល គឺ(១)-កម្មវិធីស្តារនីតិសម្បទា (២)-អប់រំនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខាងក្រៅ (៣)-លើកកម្ពស់សេដ្ឋកិច្ច និង(៤)-កម្មវិធីលើកកម្ពស់អតីតជនរងគ្រោះ។ ទិសដៅសំខាន់ ៗ របស់កម្មវិធីលើកកម្ពស់អតីតជនរងគ្រោះគឺលើកកម្ពស់សុខុមាលភាពអតីតជនរងគ្រោះនិងជនកំពុងរងគ្រោះដោយការនាំយកសម្លេងរបស់ពួកគាត់ទៅផ្សព្វផ្សាយ និងស្វែងរកដំណោះស្រាយជូនពួកគាត់អោយបានប្រសើរជាងមុន តាមរយៈកម្មវិធីទាំង៤របស់អង្គការអាហ្វេស៊ីបកម្ពុជាដែលមានស្រាប់ខាងលើ។

ដើម្បីជាការលើកទឹកចិត្តដល់បុគ្គលិក ជាពិសេសដើម្បីបញ្ចូលជំនាញភាពជាអ្នកដឹកនាំដល់អតីតជនរងគ្រោះ និងដើម្បីអោយសំរេចបាននូវគោលដៅគន្លឹះក្នុងការលើកកម្ពស់ជនរងគ្រោះអោយក្លាយជាអតីតជនរងគ្រោះ ហើយលើកកម្ពស់អតីតជនរងគ្រោះអោយក្លាយជាផ្នែកមួយនៃដំណោះស្រាយ យើងបានតែងតាំងតម្លើងតួនាទីថ្មីដល់អតីតជនរងគ្រោះចំនួន៤នាក់ ជាប្រធានកម្មវិធីចិត្តសាស្ត្រ ប្រធានកម្មវិធីអាហារូបករណ៍សកលវិទ្យាល័យនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខាងក្រៅ ប្រធានកម្មវិធីអប់រំសហគមន៍ ចុងភៅ និងបុគ្គលិកចំនួន២នាក់ទៀត ជាបុគ្គលិកថែទាំពេលថ្ងៃ និងជាបុគ្គលិកកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច ហើយតួនាទីថ្មីនេះនឹងចូលជាធរមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១នេះតទៅ ដើម្បីបំពេញនូវតម្រូវការនៃស្ថានភាពជាក់ស្តែងរបស់កម្មវិធី។

មានរបកគំហើញមួយចំនួន យើងទទួលបានពីការវាយតម្លៃ ដែលយើងបានធ្វើជាមួយអ្នកទទួលផលពីកម្មវិធី រួមមាននិស្សិតអាហារូបករណ៍សកលវិទ្យាល័យ ប្រធានក្រុមដឹកនាំប្រចាំមណ្ឌល កុមារីកំពុងសិក្សាថ្នាក់ទី១១និង១២ស្នាក់នៅក្នុងមណ្ឌល កុមារីកំពុងសិក្សានៅសហគមន៍ យុវនារី និងកុមារីសមាហរណកម្ម ដែលយើងត្រូវធ្វើការបកស្រាយជូនពួកគាត់ ត្រូវពង្រឹងការអនុវត្ត និងត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាពសំរាប់ឆ្នាំអនុវត្តឆ្នាំ២០២១។

ផលប៉ះពាល់ពីការផ្ទុះឡើងមេរោគ(វីរុស)កូវីដ-១៩ យើងបានផ្តល់អាទិភាពជួយដល់យុវនារី និងកុមារីដែលយើងធ្វើការជាមួយ(កំពុងស្នាក់នៅ)នៅក្នុងមណ្ឌល ទុំឌី ដោយការរៀបចំយុទ្ធសាស្ត្រឡើងវិញ និងការកាត់បន្ថយប្រតិបត្តិការមួយចំនួនរបស់អង្គការ ដូចជាកាត់ថវិកា និងសកម្មភាពមួយចំនួនជាដើម ចាប់ពីខែមេសាឆ្នាំ២០២០តទៅ រួមមាន កាត់ការជួលគ្រូបាំប្រពៃណីខ្មែរដើម្បីហ្វឹកហ្វឺនដល់កុមារី ផ្អាក់ការហ្វឹកហ្វឺនយោគៈ និងកីឡាតៃក្វាន់ដូជាបណ្តោះអាសន្ន កាត់ខ្ទង់ថវិកាសំរាប់ទិញឯកសណ្ឋានសិស្សនិងសម្ភារសិក្សាហើយយើងនឹងធ្វើការស្នើរសុំការបរិចាកពីសប្បុរសជនតាមបណ្តាញសង្គមហ្វេប៊ុកនៅពេលសាលារៀនចាប់ផ្តើមបើកឡើងវិញ កាត់បន្ថយរបបម្ហូបប្រចាំថ្ងៃពី៥០០០រៀលមកនៅត្រឹម៣០០០រៀលក្នុងមួយថ្ងៃពីខែមេសាដល់ខែធ្នូ កាត់ការរៀនគួបន្ថែមសំរាប់កុមារីដែលសិក្សាថ្នាក់ទី៦ ៩ និង១២ កាត់ការឧបត្ថម្ភប្រចាំខែសំរាប់សមាជិកប្រធានក្រុមប្រចាំមណ្ឌល កាត់ការឧបត្ថម្ភប្រចាំខែសំរាប់

និស្សិតអាហារូបករណ៍សកលវិទ្យាល័យ ពីព្រោះពួកគាត់ត្រូវស្នាក់នៅ ទទួលការឧបត្ថម្ភរបបអាហារប្រចាំថ្ងៃ និងការសិក្សាតាមអនឡាញនៅក្នុងមណ្ឌល កាត់ការឧបត្ថម្ភប្រចាំខែសំរាប់យុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅដោយបញ្ជូនពួកគាត់ទៅរស់នៅជាមួយក្រុមគ្រួសារវិញជាបណ្តោះអាសន្ន កាត់ខ្ទង់ថវិកាទិញស្រោមអនាម័យពីកម្មវិធីក្រុមគោលដៅ កាត់ការចុះបេសសកម្មដែលមិនចាំបាច់ សន្សំសំចៃការប្រើប្រាស់ថាមពលអគ្គិសនីនិងទឹក បញ្ចប់កិច្ចសន្យាការងារជាមួយសន្តិសុខនៅមណ្ឌលកំពង់ចាម កាត់ថ្លៃការប្រើប្រាស់ទូរស័ព្ទរបស់បុគ្គលិកទាំងអស់ចំនួន៥០%ពីខែមេសាដល់ខែតុលា កាត់បៀវត្សប្រចាំខែរបស់បុគ្គលិកទាំងអស់ចំនួន៥០%ពីខែមេសាដល់ខែតុលា និងបិទកម្មវិធីហាងអ៊ុតសក់វិមាននៅខេត្តសៀមរាបជាអចិន្ត្រៃយ៍ និងបញ្ចប់កិច្ចសន្យាការងារជាមួយបុគ្គលិក ។ល។

ដើម្បីការពារបង្ការ ការឆ្លងវីរុស (មេរោគ) កូវីដ-១៩ យើងបានផ្អាកសកម្មភាពមួយចំនួន ដូចជា ការទៅលេងគ្រួសាររបស់កុមារី ការទទួលកុមារីថ្មីចូលមណ្ឌល ការចូលទៅបំភ្លឺ(ផ្តល់សក្ខីកម្ម) និងចូលរួមសវនាការ (ជំនុំជម្រះ) របស់កុមារី សមាហរណកម្មកុមារីត្រឡប់ទៅក្រុមគ្រួសារវិញ ការបញ្ជូនកុមារីទៅពិនិត្យសុខភាពនៅខាងក្រៅ ផ្អាកសកម្មភាពកម្មវិធីក្រុមគោលដៅនៅដើមខែមិនា ផ្អាកបុគ្គលិកទៅចូលរួមប្រជុំនៅខាងក្រៅជាបណ្តោះអាសន្នបើមិនចាំបាច់ ។ គ្រប់បុគ្គលិក យុវនារី និងកុមារី ទាំងអស់ត្រូវអនុវត្តអោយបានតឹងរឹងបំផុតនូវវិធានការ គោលការណ៍អនាម័យ របស់ក្រសួងសុខាភិបាល ដោយការវាស់កំដៅនៅពេលបុគ្គលិកចូលធ្វើការ ពាក់ម៉ាស់មុខ សំអាតដៃដោយការប្រើប្រាស់ដែលឬអាល់កុលសម្លាប់មេរោគអោយបានញឹកញាប់បំផុតតាមតែអាចធ្វើបាន ។ មិនអនុញ្ញាតអោយបុគ្គលិកទាំងអស់ទៅចូលរួមព្រឹត្តិការណ៍សាធារណៈ ឬចេញទៅតាមតំបន់សាធារណៈទីប្រជុំជនមានហ្វូងមនុស្សច្រើន ។ យើងបានបិទមណ្ឌលមិនទទួលភ្ញៀវ ប៉ុន្តែនៅពេលមានករណីចាំបាច់យើងបានអនុវត្តវិធានការដ៏តឹងរឹងបំផុត នូវគោលការណ៍អនាម័យរបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**៣.១.១ កម្មវិធីស្តារនីតិសម្បទា**-មានកុមារីចំនួន៨៧នាក់ មកពី២២ខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា បានទទួលរបបអាហារប្រចាំថ្ងៃ ក្នុង១ថ្ងៃ៣ពេល សរុបចំនួន៦៨,៣១០ពេល និង បង្អែមផ្លែឈើស្រស់ប្រចាំសប្តាហ៍ចំនួន១០៦ដង តួលេខនេះមិនរាប់បញ្ចូលរបបអាហារ បង្អែមផ្លែឈើដែលបណ្តាសប្បុរសជននានាបានរៀបចំផ្តល់អោយកុមារី និងបុគ្គលិកញាំទេ បានទទួលការស្នាក់នៅជំរកសុវត្ថិភាព និង សេវាកម្មការស្តារនីតិសម្បទាផ្សេង ៗ ទៀតនៅក្នុងមណ្ឌលស្តារនីតិសម្បទា ទុំឌី ។ ក្នុងនោះមានកុមារីចំនួន៦៤នាក់ នៅសល់ពីចុងខែធ្នូ ឆ្នាំ២០១៩ និងកុមារីចំនួន២៣នាក់(ក្នុងនោះមានកុមារី២ទទួលចូលមណ្ឌលជាលើកទី២ដោយមានស្ថានភាពហានិភ័យ)ផ្សេងទៀត ជាកុមារីចូលថ្មីនៅក្នុងមណ្ឌល ទុំឌី ក្នុងឆ្នាំ២០២០។ កុមារីចំនួន២៤នាក់បានបញ្ជូនចេញពីមណ្ឌល ហើយកុមារីចំនួន៦៣នាក់ទៀតកំពុងបន្តស្នាក់នៅក្រោមការថែទាំ នៅមណ្ឌល ទុំ ឌី នៅឆ្នាំ២០២១។ កុមារីចំនួន៥៦នាក់ដែលពាក់ព័ន្ធផ្លូវច្បាប់បានទទួលជំនួយផ្នែកច្បាប់តាមនីតិវិធីច្បាប់នៅតុលាការ។ កុមារីចំនួន៩៦នាក់ បានទទួលការពិនិត្យ តាមដាន និង ព្យាបាលសុខភាពចំនួន៨២៩ដង។ កុមារីចំនួន៩៤នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសាស្ត្រ ការតាមដានបន្ត និង ការព្យាបាលតាមបែបចិត្តវិទ្យាជាលក្ខណៈឯកជននិងជាក្រុមចំនួន១៩៨ដង។ របាយការណ៍លំអិតអំពីកម្មវិធីស្តារនីតិសម្បាទា មានបរិយាយនៅទំព័រទី១៣-២២។ តារាងស្ថិតិកុមារី ដែលបានទទួលការស្នាក់នៅ ថែទាំនៅមណ្ឌល ទុំឌី ប្រចាំខែ ប្រភេទបញ្ហា និង អាយុរបស់កុមារីបង្ហាញជូនតាមតារាងខាងក្រោមនេះ។

| **តារាងស្ថិតិប្រចាំខែរបស់កុមារីដែលបានទទួលការថែទាំនៅមណ្ឌល ទុំឌី** | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ៦៤ | ៦១ | ៦១ | ៦០ | ៦២ | ៦៣ | ៦៥ | ៦២ | ៥៩ | ៦៤ | ៦២ | ៦៣ |

| តារាងបង្ហាញពីប្រភេទបញ្ហាករណី និង អាយុរបស់កុមារីដែលបានទទួលការស្នាក់នៅ ថែទាំនៅមណ្ឌល ទុំឌី | |
|---|---|
| ប្រវត្តិជួញដូរ ឬ ប្រភេទបញ្ហាករណី | កម្រិតអាយុ |
| ៧៩នាក់ រងគ្រោះដោយការរំលោភសេពសន្ថវៈ | ៦១នាក់ មានអាយុក្រោម១៥ឆ្នាំ |
| ៦នាក់ ករណីការពារបង្ការ (ហានិភ័យ) | ១៩នាក់ មានអាយុពី១៦-១៨ឆ្នាំ |
| ២នាក់ រងគ្រោះដោយការជួញដូរ | ៧នាក់ មានអាយុពី១៩-២៤ឆ្នាំ |

- រដ្ឋាភិបាលបានបន្តឧបត្ថម្ភថវិកា (ឧបត្ថម្ភដោយ លោក ហមរ៉ន ម្ចាស់គំរោងបុរីVIP) ជួលភូមិគ្រឹះ១ខ្នង សំរាប់អោយកុមារីស្នាក់នៅរហូតដល់មណ្ឌលថ្មី បានសាងសង់រួចរាល់ជាស្ថាពរ។
- អាការថ្មី១ខ្នងកម្ពស់៣ជាន់មាន៤១បន្ទប់សាងសង់សំរេចបានប្រហែល៨៥%ហើយអាចចូលនៅបានក្នុងត្រីមាសទី២ឆ្នាំ២០២១
- រាជរដ្ឋាភិបាលកម្ពុជាបន្តជួយឧបត្ថម្ភរបបអង្ករប្រចាំខែក្នុង១ខែចំនួន១,២០០គីឡូក្រាម
- សម្តេចតេជោហ៊ុនសែនបានបន្តជួយថវិកាប្រចាំខែ១នាក់ចំនួន១០០,០០០រៀលដល់កុមារីចំនួន១១៩នាក់
- រាជរដ្ឋាភិបាលកម្ពុជាបានបន្តឧត្ថម្ភថ្លៃម្ហូបប្រចាំខែក្នុង១ខែចំនួន១០,០០០,០០០.០០រៀល
- កាកបាតក្រហមកម្ពុជាបានបន្តឧបត្ថម្ភប្រចាំឆ្នាំក្នុង១ឆ្នាំចំនួន៣០,០០០,០០០.០០រៀល
- ក្រុមហ៊ុនសម្រស់ធម្មជាតិអាហារបំប៉នសារ៉ាយសមុទ្រយូស៊ីបានឧបត្ថម្ភរថយន្តថ្មី១គ្រឿងម៉ាកMazda សេរីឆ្នាំ២០២១ដល់អង្គការអាហ្វេស៊ីបកម្ពុជាដើម្បីបំរើសកម្មភាពប្រចាំថ្ងៃរបស់អង្គការ។ នេះជាក្រុមហ៊ុនក្នុងស្រុកមុនដំបូងគេបង្អស់ដែលបានជួយដល់អង្គការហើយក្រុមហ៊ុននឹងបន្តជួយឧបត្ថម្ភជាថវិកាដល់អង្គការអាហ្វេស៊ីបកម្ពុជាសំរាប់រយៈពេល១០ឆ្នាំបន្តទៀត។

**៣.១.២ កម្មវិធីអប់រំ និង បណ្តុះបណ្តាល**-កុមារីចំនួន៦៦នាក់ នៃចំណោមកុមារីទាំងអស់ (៨៧នាក់) បានទទួលការសិក្សាអប់រំក្នុងប្រព័ន្ធ និងយុវនារីចំនួន៦នាក់ទៀត បានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅខាងក្រៅនៅតាមបណ្តាហាងអ្នកផ្តល់សេវាកម្មវិជ្ជាជីវៈផ្សេង ៗ នៅពេលពួកគេស្នាក់នៅក្នុងមណ្ឌលស្តារនីតិសម្បទា ទុំឌី បន្ទាប់ពីពួកគាត់បានទទួលការព្យាបាលសះស្បើយពី របួសផ្លូវកាយ និង ផ្លូវចិត្ត។ កុមារីចំនួន៦៣នាក់ បានទទួលការសិក្សាអប់រំក្នុងប្រព័ន្ធនៅតាមសហគមន៍ ដែលពួកគាត់កំពុងរស់នៅជាមួយក្រុមគ្រួសារ ក្រោយពីពួកគាត់បានជាសះស្បើយ ពីជម្ងឺផ្លូវកាយ-ផ្លូវចិត្ត និង ទទួលបានការបញ្ជាក់អំពីសុវត្ថិភាពរបស់ពួកគាត់ថាអាចវិលត្រឡប់ទៅរស់នៅតាមសហគមន៍វិញបាន ហើយមានយុវនារីចំនួន១១នាក់ផ្សេងទៀត បានទទួលការសិក្សាថ្នាក់ឧត្តមសិក្សានៅតាមបណ្តាសកលវិទ្យាល័យនានា។ មានកុមារីចំនួន៨២នាក់ បានសិក្សាភាសាអង់គ្លេស និង កុមារីចំនួន៩៦នាក់ បានសិក្សាកំព្យូទ័រ។ មានកុមារីចំនួន៧៤នាក់ បានចូលអានសៀវភៅ និងឧបករណ៍សិក្សាផ្សេងៗ នៅក្នុងបណ្ណាល័យនៅមណ្ឌល ទុំឌី។ យើងមិនទាន់បានឧបត្ថម្ភសម្ភារៈសិក្សាជូនដល់កុមារីទាំងអ្នកស្នាក់នៅក្នុងមណ្ឌល និងកុមារីទទួលការសិក្សាអប់រំនៅសហគមន៍ ទេ ដោយបញ្ហាការផ្ទុះឡើងមេរោគកូវីដ-១៩ ហើយសាលាទូទាំងប្រទេសត្រូវបានបិទទ្វារ យើងនឹងចែកជូនពួកគាត់នៅពេលសាលាបើកឡើងវិញនៅខែមករាឆ្នាំ២០២១។ របាយការណ៍លំអិតអំពីកម្មវិធីវិធីអប់រំ និង បណ្តុះបណ្តាលមានបរិយាយនៅទំព័រទី២២-២៨។

**៣.១.៣ កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច**-កុមារីចំនួន២៧នាក់បានទៅលេងគ្រួសារចំនួន៣១ដង កុមារី និង យុវនារីចំនួន២៦នាក់ (២នាក់ពីការហ្វឹកហ្វឺនជំនាញខាងក្រៅ) បានធ្វើសមាហរណកម្មដោយទទួលបានការឧបត្ថម្ភការងារ

ការសិក្សាអប់រំនៅសហគមន៍ ត្រឡប់ទៅគ្រួសារនៅតាមសហគមន៍វិញ និង បញ្ជូនទៅទទួលការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ។ យុវនារីចំនួន៣៧នាក់ ដែលបានសមាហរណកម្មដោយការឧបត្ថម្ភមុខរបរខ្នាតតូច និង ការងារ បានទទួលការតាមដានបន្តចំនួន១០៦ដង។ គ្រួសារកុមារីអប់រំសហគមន៍ ចំនួន១គ្រួសារ បានទទួលការឧបត្ថម្ភជំនួយគ្រួសារ និងយុវនារីបានធ្វើសមាហរណកម្មចំនួន៥នាក់ បានទទួលជំនួយឧបត្ថម្ភបន្ថែមក្រោយពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។ កុមារី និង យុវនារីបានសមាហរណកម្មរួចហើយចំនួន១២៥នាក់ នឹងទទួលបានការតាមដានបន្តសំរាប់ឆ្នាំ២០២១។ របាយការណ៍ពិស្តារអំពីកម្មវិធីលើកកម្ពស់សេដ្ឋកិច្ចមានបរិយាយនៅទំព័រទី២៨-៣០។

**៣.១.៤ កម្មវិធីក្រុមគោលដៅ**-បុគ្គលិក និង សមាជិកក្រុមអប់រំមិត្តរបស់កម្មវិធីក្រុមគោលដៅ បានចុះផ្តល់ការអប់រំដល់ស្ត្រីបំរើសេវាកំសាន្តសប្បាយ (ស្ត្រីរកស៊ីផ្លូវភេទ) ចំនួន៣,៧៨៨នាក់ និង បានផ្តល់សារអប់រំទាំង៥ (ហ៊ីវ/អេដស៍ ជម្ងឺកាមរោគ ការប្រើប្រាសសារធាតុញៀន អនាម័យខ្លួនប្រាណ សិទ្ធិមនុស្ស និង ស្វ័យការពារ) ដល់ពួកគាត់នៅតាមបណ្តាទីតាំងកំសាន្តសប្បាយផ្សេងៗ ចំនួន៣២៣ទីតាំង (វិស័យឧស្សាហកម្មផ្លូវភេទ) នៅរាជធានីភ្នំពេញ ។ យើងបានផ្តល់ស្រោមអនាម័យចំនួន៧,៥១៤ស្រោម (៣ប្រអប់ធំ) សាប៊ូដុំចំនួន៣៥៩ដុំ ប្រាស និងថ្នាំដុសធ្មេញចំនួន១៣២ ដល់ស្ត្រីបំរើសេវាកំសាន្តសប្បាយ។ បានបញ្ជូនស្ត្រីបំរើសេវាកំសាន្តសប្បាយដែលយើងបានចុះអប់រំនៅតាមទីតាំងចំនួន១០៧នាក់ ទៅទទួលសេវាសុខភាពនៅតាមបណ្តាមណ្ឌលសុខភាព និង មន្ទីរពេទ្យចំនួន១៣៩ដង។ យើងបានបញ្ចុះបញ្ចូលដល់ស្ត្រីបំរើសេវាកំសាន្តសប្បាយដែលយើងបានផ្តល់ការអប់រំចំនួន១នាក់អោយបោះបង់ចោលមុខរបរពេស្យាកម្ម ហើយបានចាប់យកមុខរបរផ្សេង ដើម្បីទ្រទ្រង់ជីវភាពប្រចាំរបស់គាត់។ របាយការណ៍លំអិតអំពីកម្មវិធីក្រុមគោលដៅមានបរិយាយនៅទំព័រទី៣០-៣១។

## ៣.២ សមិទ្ធិផលសំរេចបាន

តារាងខាងឆ្វេង នៅខាងក្រោមនេះ គឺជាសុច្ចនៈករំពឹងទុក ដែលយើងបានចងក្រងឡើងជាមួយបណ្តាប្រធានកម្មវិធីទាំងអស់ នៅក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំដែលបានប្រព្រឹត្តទៅ នៅភោជនីយដ្ឋាន ម៉ម ការហ្វេ នៅរាជធានីភ្នំពេញ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ ហើយតារាងខាងស្តាំគឺបង្ហាញអំពីសមិទ្ធិផលសំរេចបាននូវសុច្ចនៈរំពឹងទុកនីមួយ ៗ ឬ ផែនការដែលបុគ្គលិកកម្មវិធីនីមួយ ៗ អនុវត្តបាន។

| **សុច្ចនៈករំពឹងទុក ឆ្នាំ២០២០** | **សមិទ្ធិផលសំរេចបាន ឆ្នាំ២០២០** |
|---|---|
| **៣.២.១ កម្មវិធីស្តារនីតិសម្បទា** | |
| 3.2.1.1 យើងនឹងជួលបុគ្គលិកចំនួន៩នាក់អោយបំរើការនៅមណ្ឌលទុំឌី ដើម្បីផ្គត់ផ្គង់អាហារប្រចាំថ្ងៃ ផ្តល់ការថែទាំ សន្តិសុខ សុវត្ថិភាព កន្លែងស្នាក់នៅ អនាម័យ មធ្យោបាយធ្វើដំណើរប្រចាំថ្ងៃ ការអប់រំ គ្រឿងឧបភោគ-បរិភោគប្រចាំថ្ងៃ និងការបង្រៀនបំណិនជីវិតផ្សេងៗដល់យុវនារី និង កុមារីនៅក្នុងមណ្ឌលទុំឌីៈ | 3.2.1.1 យើងបានជួលបុគ្គលិកចំនួន៩នាក់ អោយបំរើការនៅមណ្ឌលទុំឌី ដើម្បីផ្គត់ផ្គង់អាហារប្រចាំថ្ងៃ ផ្តល់ការថែទាំ ផ្តល់សន្តិសុខ សុវត្ថិភាព កន្លែងស្នាក់នៅ អនាម័យ មធ្យោបាយធ្វើដំណើរប្រចាំថ្ងៃ ផ្តល់ការអប់រំ ផ្គត់ផ្គង់គ្រឿងឧបភោគ-បរិភោគប្រចាំថ្ងៃ និងផ្តល់ការបង្រៀនបំណិនជីវិតផ្សេងៗ ដល់យុវនារី និង កុមារីនៅក្នុងមណ្ឌលទុំឌីៈ |

| | |
|---|---|
| - ប្រធានមណ្ឌល ១រូប<br>- បុគ្គលិកថែទាំ ២រូប<br>- បុគ្គលិកគាំពារផ្នែកច្បាប់ ១រូប<br>- សន្តិសុខ ២រូប (យប់១ និង ថ្ងៃ១)<br>- ចុងភៅ ១រូប<br>- បុគ្គលិកបើកបរ ២រូប | - ប្រធានមណ្ឌល ១រូប<br>- បុគ្គលិកថែទាំ ២រូប<br>- បុគ្គលិកគាំពារផ្នែកច្បាប់ ១រូប<br>- សន្តិសុខ ២រូប (យប់១ និង ថ្ងៃ១)<br>- ចុងភៅ ១រូប<br>- បុគ្គលិកបើកបរ ២រូប<br>**កំណត់ចំណាំ:** ប្រធានមណ្ឌលមានតួនាទីសំខាន់២យ៉ាង ជាគិលានុបដ្ឋាយិកា និង ជាប្រធានគ្រប់គ្រងមណ្ឌលទុំឌី។ |
| 3.2.1.2 យើងនឹងផ្តល់ការស្តារនីតិសម្បទាដល់យុវនារី និង កុមារី ចំនួន៨០នាក់ នៅមណ្ឌលទុំឌី។ ក្នុងនោះយុវនារី និង កុមារីចំនួន២៥នាក់ជាអ្នកចូលថ្មីក្នុងឆ្នាំ២០២០ ហើយ ៥៥នាក់ ទៀតជាយុវនារី និង កុមារីសល់ពីចុងឆ្នាំ២០១៩។ | 3.2.1.2 មានយុវនារី និង កុមារី ចំនួន៨៧នាក់ បានទទួលសេវាកម្មស្តារនីតិសម្បទា នៅមណ្ឌលទុំឌី។ ក្នុងនោះ៦៤នាក់ ជាយុវនារី និង កុមារីសល់ពីចុងខែធ្នូ ឆ្នាំ២០១៩ និង ២៣នាក់ (២នាក់ទទួលចូលមណ្ឌលវិញ) ទៀតជាអ្នកចូលថ្មី ក្នុងឆ្នាំ២០២០ ។<br><br>មានយុវនារី និង កុមារីចំនួន២៤នាក់ ក្នុងចំណោមយុវនារី និង កុមារីទាំង៨៧នាក់ បានបញ្ជូនចេញពីមណ្ឌល។ សូមមើលរបាយការណ៍ពិស្តារនៅផ្នែកកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច នៅទំព័រទី២៨-៣០។ មានយុវនារី និង កុមារីចំនួន៦៣នាក់កំពុងបន្តស្នាក់នៅ និងទទួលការថែទាំនៅមណ្ឌលទុំឌី នៅចុងខែធ្នូ ឆ្នាំ២០២០។ |
| 3.2.1.3 យើងនឹងរៀបចំការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ចំនួន២ដងសំរាប់កុមារីក្នុងមណ្ឌលទុំឌី ជារៀងរាល់៦ខែម្តង ដែលប្រារព្ធឡើងដោយយុវនារី និង កុមារីផ្ទាល់ ដើម្បីជ្រើសរើសតំណាងជាមេក្រុមដឹកនាំប្រចាំមណ្ឌលក្នុងគោលបំណង បញ្ជ្រាបមូលដ្ឋានទស្សនៈទានជាអ្នកដឹកនាំ ។ | 3.2.1.3 យើងមិនបានរៀបចំការបោះឆ្នោតទេដោយសារបញ្ហារាតត្បាតមេរោគកូវីដ-១៩ ។ |
| 3.2.1.4 យើងនឹងជួលគ្រូបង្រៀនរបាំប្រពៃណីខ្មែរពាក់កណ្តាលពេលចំនួន២នាក់ ដើម្បីមកបង្ហាត់របាំប្រពៃណីខ្មែរ ដល់យុវានរី និង | 3.2.1.4 យើងបានជួលគ្រូបង្រៀនរបាំប្រពៃណីខ្មែរពាក់កណ្តាលពេលចំនួន២នាក់ មកបង្ហាត់របាំប្រពៃណីខ្មែរ ដល់យុវនារី និង កុមារីចំនួន៤៧នាក់ នៅមណ្ឌលទុំឌី រៀងរាល់ថ្ងៃអាទិត្យ។ តែយើង |

| | |
|---|---|
| កុមារី យ៉ាងតិចចំនួន៥០នាក់នៅមណ្ឌលទុំឌីជារៀងរាល់ថ្ងៃអាទិត្យ។ | បានផ្អាកសកម្មភាពនេះនៅដើមខែមិនាដោយបញ្ហាការផ្ទុះឡើងមេរោគកូវីដ-១៩។ |
| 3.2.1.5 យើងនឹងរៀបចំការកំសាន្តសប្បាយផ្សេងៗចំនួន៤ដង អោយយុវនារី និង កុមារី ដែលស្ថិតនៅក្រោមការថែទាំនៅមណ្ឌលទុំឌី អោយបានទទួលការកំសាន្តសប្បាយ និង សំរាក់លំហែរ ដូចជា បុណ្យចូលឆ្នាំប្រពៃណីខ្មែរ ទិវាសិទ្ធិកុមារអន្តរជាតិ បុណ្យភ្ជុំបិណ្ឌ និង ការប្រារព្ធពិធីឆ្លងឆ្នាំសកល ជាដើម។ | 3.2.1.5 ដោយបញ្ហាមេរោគកូវីដ-១៩យើងមិនបានប្រារព្ធពីធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ តែយើងបានរៀបចំទិវាសិទ្ធិកុមារអន្តរជាតិដោយមានការចូលរួមតែកុមារីនិងបុគ្គលិកនៅមណ្ឌល បុណ្យភ្ជុំបិណ្ឌយើងបាននាំកុមារីយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត និងបានរៀបចំការឆ្លងឆ្នាំសកលនៅមណ្ឌលបន្តិចបន្តួចនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សំរាប់បុគ្គលិកនិង កុមារី។ |
| 3.2.1.6 យើងនឹងកសាងទំនាក់ទំនងល្អ និង បញ្ជ្រៀប ការយល់ដឹង អំពីសកម្មភាពការងារអង្គការអាហ្វេស៊ីបកម្ពុជា ដល់បណ្ដាអ្នកគាំទ្រ និង អង្គការដៃគូរ។ | 3.2.1.6 មានភ្ញៀវចំនួន៦៧៦នាក់ បានធ្វើទស្សនៈកិច្ចនៅមណ្ឌលទុំឌី ដើម្បីសិក្សាស្វែងយល់ អំពីសកម្មភាពការងារ អង្គការ អាហ្វេស៊ីប កម្ពុជា។ ក្នុងនោះញមានភ្ញៀវចំនួន៣៨នាក់ជាជនបរទេស ភ្ញៀវចំនួន៥៦២នាក់ជានជនជាតិកម្ពុជា និង ភ្ញៀវចំនួន៧៦នាក់ផ្សេងទៀតជាសាច់ញាតិរបស់កុមារី។ ភ្ញៀវមួយចំនួនបានផ្ដល់ម្ហូបអាហារ អង្ករ សម្ភារៈសិក្សា សម្ភារៈអនាម័យ សំលៀកបំពាក់ ផ្ដល់ការគាំទ្រ ការលើកទឹកចិត្ត និង ការជួយផ្សេងៗ តាមរយៈការផ្ដល់សេវាកម្ម និង សកម្មភាពផ្សេង ៗ ទៀត ។ល។ |
| **ការគាំពារ និង ជំនួយផ្នែកច្បាប់** | |
| 3.2.1.7 យើងនឹងផ្ដល់ជំនួនផ្នែកច្បាប់ដល់យុវនារី និង កុមារីចូលថ្មីចំនួន២៥នាក់ ដែលពាក់ព័ន្ធនីតិវិធីច្បាប់ តាមនីតិវិធីនៅតុលាការ។ | 3.2.1.7 មានយុវនារី និងកុមារី ចូលថ្មីចំនួន២១នាក់ នៅមណ្ឌលទុំឌី ដែលពាក់ព័ន្ធនីតិវិធីច្បាប់ បានទទួលជំនួយផ្នែកច្បាប់តាមនីតិវិធីនៅតុលាការ។ |
| 3.2.1.8 យើងនឹងស្នើរសុំមេធាវី ចំនួន២៨នាក់ (មេធាវី២នាក់នឹងជួលពីក្រុមហ៊ុនឯកជន) ពីបណ្ដាអង្គការ ស្ថាប័នបំរើសេវាកម្មច្បាប់ ដើម្បីជាតំណាង ការពារក្ដីអោយជនរងគ្រោះ នៅតុលាការ ។ | 3.2.1.8 មានមេធាវីចំនួន១៩នាក់ បានផ្ដល់ការគាំទ្រជាតំណាងការពារក្ដីអោយយុវនារី និង កុមារីរងគ្រោះ ចំនួន៥៦នាក់ ដែលពាក់ព័ន្ធនីតិវិធីច្បាប់នៅតុលាការ ។ កុមារីរងគ្រោះចំនួន៣៥នាក់ជាករណីចាស់សល់ពីឆ្នាំ២០១៩ និង ២១នាក់ទៀត ជាករណីថ្មីក្នុងឆ្នាំ២០២០ ដែលពាក់ព័ន្ធ |

| | |
|---|---|
| | នីតិវិធីច្បាប់។ ចារី (ឧក្រិដ្ឋជន) ចំនួន១៦នាក់ ត្រូវបានចាប់ខ្លួន និង ឃុំខ្លួន។ |
| 3.2.1.9 យុវនារី និង កុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈចំនួន២៥នាក់នឹងបានទទួលការធ្វើកោសល្យវិច្ឆ័យ ដើម្បីជាភស្តុតាងដាក់បន្ទុកប្រឆាំង (លើ) ជនជាប់ចោទតាមតម្រូវការរបស់តុលាការ។ | 3.2.1.9 មានយុវនារី និង កុមារីរងគ្រោះ ដោយការរំលោភសេពសន្ថវៈចំនួន២១នាក់ បានទទួលការធ្វើកោសល្យវិច្ឆ័យ ដើម្បីបញ្ជាក់ជាភស្តុតាងដាក់បន្ទុកប្រឆាំងជនជាប់ចោទនៅតុលាការ។ កោសល្យវិច្ឆ័យបានដោយវេជ្ជបណ្ឌិត នៅតាមបណ្ដាមន្ទីរពេទ្យខេត្ត-ក្រុង។ |
| 3.2.1.10 យុវនារី និងកុមារីរងគ្រោះចំនួន៣០នាក់នឹងទៅចូលឆ្លើយបំភ្លឺ និងចូលរួមសវនាការចំនួន៧០ដង (ជាមធ្យោម១ករណីត្រូវទៅតុលាការ២ដង (បំភ្លឺ១ដង និងសវនាការ១ដង) នៅតុលាការតាមការដីការកោះបង្គាប់របស់តុលាការ។ | 3.2.1.10 មានយុវនារី និង កុមារីរងគ្រោះចំនួន៥៨នាក់ បានចូលទៅឆ្លើយបំភ្លឺ និងចូលរួមសវនការបានចំនួន៥៤ដង។ ក្នុងនោះមានកុមារីរងគ្រោះចំនួន២៥នាក់ បានចូលទៅឆ្លើយបំភ្លឺនៅតុលាការបានចំនួន២៤ដង ហើយកុមារីចំនួន៣៣នាក់បានទៅចូលរួមសវនាការ (ជំនុំជម្រះ) បានចំនួន៣០ដង នៅតុលាការ នៅតាមបណ្ដាខេត្ត-ក្រុង តាមការដីការកោះបង្គាប់របស់តុលាការ។<br><br>ជនជាប់ចោទចំនួន២៧នាក់ ត្រូវបានតុលាការកាត់ទោស អោយជាប់ព័ន្ធនាគារដោយកំរិតទោសខ្ពស់បំផុត១៤ឆ្នាំ និង ទាបបំផុត ៤ឆ្នាំ។ |
| 3.2.1.11 យុវនារីនិងកុមារីចំនួន៥៥នាក់នឹងទទួលបានការតាមដានបន្តករណីពាក់ព័ន្ធ និងនីតិវិធីច្បាប់ ជាមួយមេធាវី និង តុលាការចំនួន២៥០ដង។ | 3.2.1.11 យើងបានធ្វើការតាមដានករណី យុវនារី និង កុមារី រងគ្រោះដែលពាក់ព័ន្ធនីតិវិធីច្បាប់ចំនួន៥១នាក់ បានចំនួន៣៣៥ដង ជាមួយមេធាវីភាគច្រើនយើងធ្វើតាមរយៈទូរស័ព្ទ។ |
| 3.2.1.12 យើងនឹងផ្ដល់ព័ត៌មាន អំពីដំណើរការករណីពាក់ព័ន្ធច្បាប់ ជូនដល់ក្រុមគ្រួសារ យុវនារី និង កុមារីរងគ្រោះចំនួន២០គ្រួសារ។ | 3.2.1.12 យើងបានផ្ដល់ព័ត៌មាន ដល់សមាជិកក្រុមគ្រួសារ យុវនារី និង កុមារីរងគ្រោះបានចំនួន២៧គ្រួសារ អំពីលទ្ធផលនៃការប្រកាសសាលក្រមរបស់តុលាការចំនួន២៧ករណី ក្រោយការបើកសវនាការជំនុំជំរះនៅតុលាការ។ |

| | | | |
|---|---|---|---|
| 3.2.1.13 | យើងនឹងមានការប្រជុំចំនួន២៥ដងជាមួយមន្ត្រីមន្ទីរសង្គមកិច្ចខេត្ត-ក្រុង និងបណ្ដាអង្គការនានា អំពីភាពជាដៃគូរក្នុងការបញ្ជូនករណីជនរងគ្រោះមកកាន់អង្គការ អាហ្វេស៊ីប កម្ពុជា ការធ្វើបទបង្ហាញអំពីសកម្មភាពការងារ អង្គការ អាហ្វេស៊ីប ជូនពួកគាត់ និងដើម្បីសិក្សាស្វែងយល់ពីគ្នាទៅវិញទៅមក។ | 3.2.1.13 | យើងបានប្រជុំជាមួយមន្ត្រីមន្ទីរសង្គមកិច្ច និងអាជ្ញាធរមូលដ្ឋាន ខេត្ត-ក្រុងទាំងការជួបផ្ទាល់ និងតាមទូរស័ព្ទបានចំនួន២១ដង ជាពិសេសនៅពេលបុគ្គលិករបស់យើងបានចុះទៅទទួលយកយុវនារី និង កុមារីរងគ្រោះចូលថ្មី នៅតាមមូលដ្ឋានចូលមណ្ឌល ហើយយើងក៏បានធ្វើបទបង្ហាញ អំពីសកម្មភាពការងាររបស់អង្គការអាហ្វេស៊ីប កម្ពុជា ជូនពួកគាត់ផងដែរ។ |
| **ការពិនិត្យ និង ព្យាបាលសុខភាព** | | | |
| 3.2.1.14 | យើងនឹងជួលបុគ្គលិកផ្នែកសុខភាពចំនួន២នាក់អោយបំរើការនៅមណ្ឌលទុំឪ ដើម្បីផ្ដល់ការថែទាំសុខភាពដល់យុវនារី និង កុមារីដែលស្នាក់នៅមណ្ឌល យុវនារីរៀនជំនាញនៅខាងក្រៅ អាហារូបករណ៍សកលវិទ្យាល័យ កុមារីសិក្សាអប់រំនៅតាមសហគមន៍ យុវនារី និងកុមារីដែលបានធ្វើសមាហរណកម្មត្រឡប់ទៅកាន់សហគមន៍វិញ។ | 3.2.1.14 | យើងបានជួលបុគ្គលិកចំនួន២នាក់អោយបំរើការនៅផ្នែកសុខភាព។ ១នាក់ជាវេជ្ជបណ្ឌិតធ្វើការពាក់កណ្ដាលពេលនៅចុងសប្ដាហ៍ ប៉ុន្តែគាត់អាចមកជួយយើងបានគ្រប់ពេលនៅមានតម្រូវការចាំបាច់ និង ម្នាក់ទៀតជាគិលានុបដ្ឋាយិកា បានបញ្ចប់បរិញ្ញាប័ត្រ ផ្នែកគិលានុបដ្ឋាក ។ |
| 3.2.1.15 | យ៉ាងហោចណាស់ នឹងមានយុវនារី និងកុមារីចូលថ្មីនៅមណ្ឌល ទុំឪ ចំនួន៩0% (២៥ នៃ ចំនួន៨0នាក់) នឹងទទួលបានការថែទាំ ពិនិត្យ និង ព្យាបាលសុខភាព។ | 3.2.1.15 | ១00%ក្នុងចំណោមយុវនារី និង កុមារីចូលថ្មីទាំងអស់ ចំនួន២៣នាក់ (២នាក់ចូលមណ្ឌលលើកទី២) នៅមណ្ឌល ទុំឪ បានទទួលការពិនិត្យ និង ព្យាបាលសុខភាពទូទៅ នៅពេលពួកគាត់ចូលមកដល់មណ្ឌល។ |
| 3.2.1.16 | យុវនារី និងកុមារីចំនួន៧៥នាក់ នឹងទទួលបានការតាមដាន ការពិនិត្យ និងព្យាបាលសុខភាពបន្ត តាមតម្រូវការជាក់ស្ដែងរបស់ករណីនីមួយ ៗ។ | 3.2.1.16 | យើងបានផ្ដល់ការពិនិត្យតាមដាន ការថែទាំ និង ពិនិត្យព្យាបាលសុខភាព ចំនួន៨0៥ដងដល់យុវនារី និង កុមារីស្នាក់នៅក្នុងមណ្ឌលទុំឪ បានចំនួន៨៣នាក់ តាមតម្រូវការជាក់ស្ដែងរបស់ករណីនីមួយ ៗ ។<br><br>កុមារីចំនួន៧នាក់ បានចូលសំរាកព្យាបាលនៅមន្ទីរពេទ្យកុមារជាតិ និងមជ្ឈមណ្ឌលវះកាត់កម្ពុជា ដើម្បីព្យាបាលដៃបាក់ វះកាត់ប្រដាប់ភេទដែលខុសប្រក្រតី ព្យាបាលមាត់ឆែប ជំងឺ |

| | | | |
|---|---|---|---|
| | | | ស្នះក្រពេញទឹកភ្នែក ការឆ្លុះមើលពោះវៀនធំ និងជំងឺឆ្អួតជ្រួក។<br><br>យុវនារី និងកុមារីចំនួន៣០នាក់ បានទទួលការកក់សក់សំអាតចៃ និងប៉ារ៉ាស៊ីត។<br><br>យុវនារី និងកុមារីចំនួន៦៥នាក់ បានទទួលការសិក្សាបំណិនជីវិតចំនួន៨វគ្គ អំពីការថែ ទាំសុខភាពបឋម ដូចជា ការការពារបង្ការមេរោគកូវីដ-១៩ ការពាក់ម៉ាស់មុខ ការការពារកាំរស្មីយូវី ការសំអាតដោយក្លរ(chloride) ការលាយអាល់កុល ការពន្យាកំណើត ជម្ងឺគ្រុនពោះវៀន អនាម័យមាត់ធ្មេញ (ការដុសធ្មេញ) និង៦វិធីនៃការលាងដៃ។ |
| 3.2.1.17 | យុវនារី និងកុមារីចំនួន១០៥នាក់ (កុមារក្នុងមណ្ឌលចំនួន៦០នាក់ អប់រំសហគមន៍ចំនួន៣០នាក់ និង១៥នាក់ទៀតជាយុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅនិងនិស្សិតអាហារូបករណ៍) នឹងទទួលបានការចាក់ថ្នាំបង្ការជំងឺផ្តាសាយ។ | 3.2.1.17 | យុវនារី និងកុមារីចំនួន៦៧នាក់ បានទទួលការចាក់ថ្នាំបង្ការជម្ងឺគ្រុនផ្តាស់សាយ។ |
| 3.2.1.18 | កុមារីចំនួន៨០នាក់នឹងទទួលបានការចាក់ថ្នាំបង្ការជមងឺតេតាណូស ។ កុមារីចំនួន៨០នាក់នឹងទទួលបានការចាក់ថ្នាំបង្ការជំងឺថ្លើមប្រភេទB ។ កុមារីចំនួន១០៥នាក់នឹងទទួលបានការចាក់ថ្នាំបង្ការជំងឺគ្រុនឈាម និង៩នាក់ទៀតនឹងទទួលការព្យាបាលផ្សេង ៗ (២នាក់នឹងទទួលថ្នាំព្យាបាលជំងឺថ្លើមប្រភេទB ២នាក់នឹងទទួលCPR និង Ultrasound សំរាប់ជំងឺថ្លើមប្រភេទB ៣នាក់នឹងទទួលសេវាពន្យាកំណើត និង២នាក់ទៀតនឹងទទួលបានការពិនិត្យរកមេរោគរបេង។ | 3.2.1.18 | យុវនារី និងកុមារីចំនួន៤៧នាក់បានទទួលការចាក់ថ្នាំបង្ការជម្ងឺតេតាណូស និង យុវនារី និងកុមារីចំនួន៤២នាក់បានទទួលការចាក់ថ្នាំបង្ការជំងឺថ្លើមប្រភេទB និងជម្ងឺគ្រុនឈាម។<br><br>យុវនារី និងកុមារីចំនួន៥៩នាក់ និងបុគ្គលិកចំនួន២៣នាក់ បានធ្វើតេស្តរកមេរោគរបេង ដោយការថតអ៊ិចសារ៉េដើមទ្រូងពិនិត្យសួត និងពិនិត្យកំហាក។ |

| | | | |
|---|---|---|---|
| 3.2.1.19 | យើងនឹងធ្វើការសហការ ជាមួយមូលនិធិគ្រួសារពិភពលោក ដើម្បីផ្តល់ការពិនិត្យ និង ព្យាបាលសុខភាពមាត់ធ្មេញ ចំនួន៤ដងដល់យុវនារី និង កុមារីចំនួន៨០នាក់ ជារៀងរាល់៣ខែម្តង។ | 3.2.1.19 | យើងបានផ្តល់ការពិនិត្យ ព្យាបាល និង ការបណ្តុះបណ្តាល អំពីការថែរក្សាសុខភាពមាត់ធ្មេញដល់យុវនារី និងកុមារីដែលស្នាក់នៅមណ្ឌលទុំឌី បានចំនួន៤ដងដល់កុមារីចំនួន៦៨នាក់ ដោយសហការជាមួយមូលនិធិគ្រួសារពិភពលោក។ |
| 3.2.1.20 | យើងនឹងផ្តល់ការពិនិត្យ និង ព្យាបាលសុខភាពភ្នែក ចំនួន២ដងដល់យុវនារី និង កុមារីចំនួន៨០នាក់ នៅមជ្ឈមណ្ឌលវះកាត់កុមារដោយមិនបង់ថ្លៃ តែយើងត្រូវចំណាយលើមធ្យោបាយធ្វើដំណើរ ភេសជ្ជៈ អាហារពេលព្រឹក និងអាហារថ្ងៃត្រង់។ | 3.2.1.20 | យើងមិនបានផ្តល់ការពិនិត្យ និង ព្យាបាលសុខភាពភ្នែកដល់យុវនារីនិងកុមារីទេដោយបញ្ហាផ្ទុះឡើងមេរោគកូវីដ-១៩ ។ |
| 3.2.1.21 | យើងនឹងផ្តល់ការពិនិត្យឈាមចំនួន២ដងក្នុង១ឆ្នាំដល់យុវនារី និងកុមារីស្នាក់នៅមណ្ឌលទុំឌីចំនួន៦០នាក់ និង យុវនារីទទួលការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈនៅខាងក្រៅ និស្សិតអាហារូបករណ៍ និងសមាហរណកម្ម ចំនួន៣០ អំពីCBC, glycaemia, Ag_Anti-HBS ។ | 3.2.1.21 | យើងមិនបានផ្តល់ការពិនិត្យឈាម អំពីCBC, glycaemia, Ag, Anti-HBS ដល់យុវនារី និងកុមារីទេដោយបញ្ហារាតត្បាតមេរោគកូវីដ-១៩ ។ |
| 3.2.1.22 | យើងនឹងផ្តល់ការពិនិត្យ មហារីកមាត់ស្បូនដល់យុវនារី និងកុមារីចំនួន៦០នាក់ ហើយយើងនឹងផ្តល់ការចាក់ថ្នាំបង្ការមហារីកមាត់ស្បូនដល់យុវនរី និងកុមារីចំនួន៦០នាក់ ។ | 3.2.1.22 | យើងបានផ្តល់ការពិនិត្យ និងធ្វើតេស្ត ហ៊ីវ (HIV) និង កាមរោគ (syphilis) ដល់យុវនារី និងកុមារីចំនួន១១នាក់នៅមណ្ឌលទុំឌី តែយើងមិនបានផ្តល់ការពិនិត្យ មហារីកមាត់ស្បូន និងចាក់ថ្នាំបង្ការមហារីកមាត់ស្បូនដល់ពួកគាត់ទេដោយបញ្ហាថវិកា។ |
| 3.2.1.23 | យុវនារី និងកុមារីចំនួន៧០នាក់ ដែលជាយុវនារី និងកុមារីសមាហរណកម្ម ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ សិក្សាអប់រំសហគមន៍ និងនិស្សិតអាហារូបករណ៍សកលវិទ្យាល័យ នឹងទទួលបានការពិនិត្យតាមដាន និងព្យាបាលសុខភាពតាមតម្រូវការជាក់ស្តែង។ | 3.2.1.23 | ផ្នែកសុខភាពយើងបានផ្តល់ការពិនិត្យ តាមដានបន្ត និង ព្យាបាលសុខភាព ដល់យុវនារី និងកុមារី សមាហរណកម្ម ហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ សិក្សាអប់រំសហគមន៍ និងនិស្សិតអាហារូបករណ៍សកលវិទ្យាល័យ បានចំនួន ២៦នាក់ នៅតាមសហគមន៍។ |

| | |
|---|---|
| **ការគាំទ្រផ្នែកចិត្តសាស្ត្រ** | |
| 3.2.1.24 យើងនឹងជួលបុគ្គលិកចិត្តសាស្ត្រចំនួន២នាក់ អោយបំរើការកម្មវិធីចិត្តសាស្ត្រ នៅមណ្ឌល ទុំឌី ។ | 3.2.1.24 យើងបានបន្ត កិច្ចសន្យាការងារជាមួយបុគ្គលិកចិត្តសាស្ត្រចំនួន២នាក់ ។ ១នាក់ធ្វើការពាក់កណ្ដាលពេលជាមួយកម្មវិធីចិត្តសាស្ត្រ និងពាក់កណ្ដាលពេលទៀត គ្រប់គ្រងកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច ព្រោះគាត់ជាប្រធានកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច។ |
| 3.2.1.25 យើងនឹងជ្រើសរើសបុគ្គលិកចិត្តសាស្ត្រស្ម័គ្រចិត្តចំនួន២នាក់ ដើម្បីជួយការងារកម្មវិធីចិត្តសាស្ត្រ យ៉ាងតិចបំផុតសំរាប់រយៈពេល៣ខែ នៅក្នុងឆ្នាំ២០២០ លើការងារយោគៈ/ហ្វឹកហ្វឺនលំហាត់សំរាក សុខភាពផ្លូវចិត្តបឋម(ល្បែងបង្កើនកំលាំ) ។ | 3.2.1.25 ដោយបញ្ហាការរាតត្បាតមេរោគកូវីដ-១៩ យើងមិនអាចជ្រើសរើសអ្នកចិត្តសាស្ត្រស្ម័គ្រចិត្តចំនួន២នាក់តាមគំរោងរបស់យើងបានទេពីព្រោះយើងត្រូវការធានានូវសុវត្ថិភាពសំរាប់កុមារីនិងបុគ្គលិក ។ |
| 3.2.1.26 យើងនឹងធ្វើការវាយតម្លៃចិត្តសាស្ត្រ ដល់យុវនារី និង កុមារីចូលថ្មី១០០% (២៥នៃ ៨០នាក់) នៅពេលពួកគេចូលមកដល់មណ្ឌលភ្លាម ។ | 3.2.1.26 មានយុវនារី និង កុមារីចូលថ្មីចំនួន២៣នាក់ (២នាក់ជាករណីទទួលចូលមណ្ឌលវិញ)ស្មើរ និង១០០% បានទទួលការវាយតម្លៃផ្នែកចិត្តសាស្ត្រ និង ពិគ្រោះយោបល់ នៅពេលចូលមកដល់មណ្ឌល ទុំឌី។ |
| 3.2.1.27 យើងនឹងផ្ដល់ការតាមដានបន្ត ពិគ្រោះយោបល់ និង ព្យាបាលសុខភាពផ្លូវចិត្ត ដល់យុវនារី និងកុមារីដែលត្រូវការជំនួយផ្នែកចិត្តសាស្ត្របន្ត១០០%តាមតម្រូវការជាក់ស្ដែង។ | 3.2.1.27 យុវនារី និង កុមារីចំនួន៩៤នាក់ បានទទួលការតាមដានបន្តផ្នែកចិត្តសាស្ត្រ ជាលក្ខណៈបុគ្គល និងជាក្រុមចំនួន១៩៨ដង។ ក្នុងនោះ៦០នាក់ជាកុមារីស្នាក់នៅមណ្ឌលទុំឌី បានទទួលការតាមដានពិគ្រោះយោបល់ចំនួន១៣៥ដង ។ |
| 3.2.1.28 យើងនឹងផ្ដល់ថ្នាក់មូលដ្ឋាននៃការថែទាំ និងព្យាបាលសុខភាពផ្លូវចិត្ត តាមបែបសកម្មភាពវិចិត្រកម្មផ្សេង ៗ ចំនួន២៤វគ្គ ដល់យុវនារី និងកុមារី ចំនួន៨០នាក់នៅមណ្ឌលទុំឌី។ | 3.2.1.28 យើងបានផ្ដល់សកម្មភាពវិចិត្រកម្មផ្សេង ៗ ដូចជា ការផាត់ពណ៌ ការគូររូបដោយសេរី ការបត់ក្រដាសធ្វើរូបផ្សេង ៗ ហត្ថកម្ម និង ការលេងកំសាន្ត។ល។ ចំនួន២១វគ្គ ដល់យុវនារី និងកុមារីចំនួន៧៥នាក់ នៅមណ្ឌលទុំឌី។ |
| 3.2.1.29 យើងនឹងបង្រៀន មេរៀនក្រុមជួយខ្លួនឯងចំនួន១២វគ្គ ដល់យុវនារី និងកុមារីចំនួន | 3.2.1.29 យើងបានបង្រៀន មេរៀនក្រុមជួយខ្លួនឯងបានចំនួន៣២វគ្គ ដល់យុវនារី និង កុមារី ចំនួន |

| | | | |
|---|---|---|---|
| | ៨០នាក់ អំពីការរំលោភបំពាន ការជួញដូរមនុស្ស អំពើហឹង្សាក្នុងគ្រួសារ គ្រួសារក្រីក្រ ការសុខភាពផ្លូវចិត្ត/ការអភិវឌ្ឍន៍កុមារ នីតិវិធីនៅតុលាការ ការផ្សាភ្ជាប់ជាមួយគ្រួសារ និងការជួយឧបត្ថម្ភនាពេលអនាគត។ | | ៧៧នាក់ ស្តីអំពីនីតិវិធីនៅតុលាការ ការកំណត់គោលដៅជីវិត ការគាំទ្រនិងលើកទឹកចិត្តក្នុងក្រុម មិត្តភាព និង ជីវិតគ្រួសារ។ |
| 3.2.1.30 | យើងនឹងផ្តល់ការតាមដានបន្ត ការពិគ្រោះយោបល់ចិត្តសាស្ត្រ ដោយផ្ទាល់ និង តាមទុរសព្ទ ដល់យុវនារី និង កុមារី ចំនួន១៨២នាក់ ។ ១២០នាក់ជាករណីសមាហរណកម្ម ៤៥នាក់ជាករណីសិក្សាអប់រំនៅសហគមន៍ ៧នាក់ជាករណីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខាងក្រៅ និង ១០នាក់ជាអាហារូបករណ៍សកលវិទ្យាល័យ ។ | 3.2.1.30 | យើងបានផ្តល់ការតាមដានបន្ត ការពិគ្រោះយោបល់ចិត្តសាស្ត្រ ដោយផ្ទាល់ និងតាមរយៈទូរសព្ទបានចំនួន៦៣ដង ដល់កុមារីបានចំនួន៤៣នាក់ ។ ២០នាក់ជាយុវនារី និងកុមារីសមាហរណកម្ម ៨នាក់សិក្សាអប់រំនៅសហគមន៍ ៧នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខាងក្រៅ និង ៨នាក់អាហារូបករណ៍សកលវិទ្យាល័យ ។ |
| 3.2.1.31 | យើងនឹងផ្តល់ការហ្វឹកហ្វឺនយោគៈ (Yoga) ចំនួន៩០វគ្គ ដល់យុវនារីនិងកុមារី នៅមណ្ឌលទំុឱ ចំនួន៨០នាក់ដោយហសការជាដៃគូរជាមួយអង្គការ Krama Yoga Cambodia។ គំរោងនេះទទួលជំនួយឧបត្ថម្ភថវិកាពី Leslies Gutson ដោយផ្តាល់ថវិកា ទៅអង្គការ Krama Yoga Cambodia ផ្ទាល់តែម្តង។ | 3.2.1.31 | យើងបានផ្តល់ការហ្វឹកហ្វឺនយោគៈចំនួន៦៨វគ្គ ដល់យុវនារី និង កុមារីចំនួន៨២នាក់ ដែលស្នាក់នៅមណ្ឌលទំុឱ។ វគ្គបណ្តុះបណ្តាលនេះបង្រៀនដោយលោកគ្រូអ្នកគ្រូ មកពីអង្គការ Krama Yoga Cambodia និងបានទទួលការឧបត្ថម្ភថវិកាពី Leslies Gutson រស់នៅទីក្រុងញ៉ីវយ៉ក។ យើងអនុវត្តបានតិចជាងផែនការរំពឹងទុក ដោយបញ្ហាផ្ទុះឡើងកូវីដ-១៩ យើងបានផ្អាកសកម្មភាពនេះមួយរយៈពេល។ |
| 3.2.1.32 | យើងនឹងផ្តល់ការពិគ្រោះយោបល់ ចិត្តសាស្ត្រ ដល់យុវនារី និង កុមារីចូលថ្មីចំនួន២០នាក់ នៅពេលធ្វើដំណើរមកស្នាក់នៅមណ្ឌល និង នៅមុនពេល អំឡុងពេល និងក្រោយពេលចូលឆ្លើយបំភ្លឺ និង ចូលរួមសវនាការនៅតុលាការ។ | 3.2.1.32 | យុវនារី និងកុមារីចំនួន៥៨នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសាស្ត្រ នៅមុនពេល អំឡុងពេល និងក្រោយពេលចូលទៅឆ្លើយបំភ្លឺ (បឋមសវនាកា និង សវនាការពេញអង្គ) នៅតុលាការ ។ ក្នុងនោះមាន២៥នាក់បានចូលទៅឆ្លើយបំភ្លឺ និង៣៣នាក់ទៀតបានចូលរួមសវនាការជំនុំជម្រះនៅតុលាការ។ |
| 3.2.1.33 | លោកស្រី Loise White ជាអ្នកស្ម័គ្រចិត្តរស់នៅប្រទេសអូស្ត្រាលី នឹងផ្តល់វគ្គបណ្តុះបណ្តាលមិត្តជួយមិត្ត ស្តីពីស្វ័យគាំពារសុខ | 3.2.1.33 | លោកស្រី Loise White ជាអ្នកចិត្តសាស្ត្រមានអាជ្ញាប័ណ្ណ រស់នៅប្រទេសអូស្ត្រាលី បានផ្តល់វគ្គបណ្តុះបណ្តាលមិត្តជួយមិត្ត តាមប្រព័ន្ធអន |

| | |
|---|---|
| ភាពផ្លូវចិត្តតាមប្រព័ន្ធអនឡាញចំនួន១០ ដង ដើម្បី ជួយដល់បុគ្គលិកចិត្តសាស្ត្ររបស់ យើងចំនួន២នាក់។ | ឡាញ បានចំនួន១ដង ស្តីពីការកំណត់បញ្ញត្តិ ការវាយកំលៃ និងស្វ័យគាំពារ ដើម្បីជួយផ្តល់ បច្ចេកទេសស្វ័យគាំពារសុខភាពផ្លូវចិត្តដល់ បុគ្គលិកចិត្តសាស្ត្ររបស់យើងទាំង២នាក់។ លោកស្រីបានផ្តល់វគ្គបណ្តុះបណ្តាលមិត្តជួយ មិត្តនេះ ដោយឥតគិតកម្រៃ។ យើងអនុវត្តវគ្គប ណ្តុះបណ្តាលមិត្តជួយមិត្តបានតិចជាងការរំពឹង ទុក ដោយសារបញ្ហាពេលវេលា បញ្ហាសុខភាព និងការផ្លាស់ទីលំនៅរបស់គ្រូបណ្តុះបណ្តាល ទៅកន្លែងថ្មី។ |
| **៣.២.២ កម្មវិធីអប់រំ និង បណ្តុះបណ្តាល**<br><br>3.2.2.1 យើងនឹងជួលបុគ្គលិកចំនួន៥នាក់អោយបំរើការកម្មវិធីអប់រំនិងបណ្តុះបណ្តាលៈ<br>- បុគ្គលិកតាមដានការសិក្សាអប់រំ ១រូប<br>- គ្រូបង្រៀនភាសាអង់គ្លេស ១រូប<br>- គ្រូបង្រៀកំព្យូទ័រ ១រូប<br>- បុគ្គលិកសិក្សាអប់រំសហគមន៍ ១រូប<br>- បុគ្គលិកអប់រំនិងបណ្តុះបណ្តាល ១រូប<br><br>3.2.2.2 យើងនឹងផ្តល់ការសិក្សាអប់រំក្នុងប្រព័ន្ធនៅសាលារដ្ឋ ដល់កុមារីចំនួន៧០នាក់ ដែលស្នាក់នៅមណ្ឌល ទុំឌី ។<br><br>3.2.2.3 យើងនឹងផ្តល់ការសិក្សាបន្ថែមដល់កុមារីនៅក្នុងមណ្ឌលចំនួន១១នាក់។ ក្នុងនោះ៩នាក់សិក្សាថ្នាក់ទី៦ ១នាក់សិក្សាថ្នាក់ទី៩ និង១នាក់ទៀតសិក្សាថ្នាក់ទី១២ ។ | 3.2.2.1 យើងបានជួលបុគ្គលិកចំនួន៥នាក់អោយបំរើការកម្មវិធីអប់រំនិងបណ្តុះបណ្តាលៈ<br>- បុគ្គលិកតាមដានការសិក្សាអប់រំ ១រូប<br>- គ្រូបង្រៀនភាសាអង់គ្លេស ១រូប<br>- គ្រូបង្រៀកំព្យូទ័រ ១រូប<br>- បុគ្គលិកសិក្សាអប់រំសហគមន៍ ១រូប<br>- បុគ្គលិកអប់រំនិងបណ្តុះបណ្តាល ១រូប<br><br>3.2.2.2 យើងបានផ្តល់ការសិក្សាអប់រំក្នុងប្រព័ន្ធនៅសាលារដ្ឋដល់កុមារីចំនួន៦៦នាក់ ដែលស្នាក់នៅមណ្ឌល ទុំឌី ក្នុងនោះកុមារីចំនួន៥៤នាក់សល់ពីចុងឆ្នាំ២០១៩ និង ១២នាក់ទៀត ជាកុមារីចូលថ្មីបានទទួលការសិក្សាអប់រំក្នុងឆ្នាំ ២០២០។<br>- ៤៨នាក់ សិក្សានៅបឋមសិក្សា<br>- ១៣នាក់ សិក្សានៅមធ្យមសិក្សា<br>- ៥នាក់ សិក្សានៅវិទ្យាល័យ<br><br>3.2.2.3 យើងបានផ្តល់ការសិក្សាបន្ថែម ដល់កុមារីចំនួន ១០នាក់ លើ៤មុខវិជ្ជាដូចជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និង ជីវវិទ្យា ក្នុងនោះមាន៨នាក់រៀនថ្នាក់៦ ១នាក់រៀនថ្នាក់ទី៩ និង ១នាក់ទៀតរៀនថ្នាក់ទី១២។ |

| | | | |
|---|---|---|---|
| 3.2.2.4 | យើងនឹងផ្តល់រង្វាន់លើកទឹកចិត្តដល់កុមារី នៅមណ្ឌលចំនួន១១នាក់ ដែលជាសិស្សរៀនពូកែប្រចាំថ្នាក់ ពីលេខ១-៣។ | 3.2.2.4 | យើងមិនបានអនុវត្តសកម្មភាពនេះទេ ដោយបញ្ហាកូវីដ-១៩ ជះឥទ្ធិពលដល់ថវិកា ។ |
| 3.2.2.5 | យើងនឹងផ្តល់ការឧបត្ថម្ភ ការផ្ទេរការសិក្សាដល់កុមារីនៅមណ្ឌលចំនួន៤នាក់ ។ | 3.2.2.5 | យើងបានឧបត្ថម្ភការផ្ទេរឯកសារសិក្សា ដល់កុមារីចូលថ្មីចំនួន១៩នាក់ សំរាប់ការចុះឈ្មោះចូលរៀននៅពេលពួកគាត់មកស្នាក់នៅមណ្ឌលទុំឌី ។ |
| 3.2.2.6 | យើងនឹងរៀបចំអោយមានការចូលអានសៀវភៅ និង ធនធានអប់រំផ្សេង ៗ នៅបណ្ណាល័យនៅក្នុងមណ្ឌល ដល់កុមារីស្នាក់នៅមណ្ឌល ទុំឌី និង កុមារមកពីសហគមន៍នៅក្បែរ ៗ មណ្ឌលប្រមាណជា២៥នាក់ ជារៀងរាល់សប្តាហ៍ ។ | 3.2.2.6 | យើងបានរៀបចំអោយមានការចូលអានសៀវភៅ និង ធនធានអប់រំផ្សេង ៗ ក្នុងបណ្ណាល័យនៅមណ្ឌលទុំឌី ដល់កុមារីចំនួន៧៤នាក់។ |
| 3.2.2.7 | យើងនឹងផ្តល់ការសិក្សាភាសាអង់គ្លេសដល់កុមារីចំនួន៨០នាក់ (ក្នុងនោះកុមារី១០នាក់មកពីសហគមន៍) នៅមណ្ឌលទុំឌី ។ | 3.2.2.7 | យើងបានផ្តល់ការសិក្សាភាសាអង់គ្លេសនៅមណ្ឌលទុំឌី ដល់កុមារីចំនួន៨២នាក់។ ក្នុងនោះមាន៦៨នាក់កុមារីស្នាក់នៅក្នុងមណ្ឌល ៦នាក់ជានិស្សិតអាហារូបករណ៍សកលវិទ្យាល័យ និង៨នាក់ទៀតជាកុមារីមកពីសហគមន៍។ |
| 3.2.2.8 | យើងនឹងផ្តល់ការសិក្សាថ្នាក់មូលដ្ឋានកំព្យូទ័រដល់កុមារីចំនួន៨០នាក់ (១០នាក់ជាកុមារីមកពីសហគមន៍) នៅមណ្ឌលទុំឌី។ | 3.2.2.8 | យើងបានផ្តល់ការសិក្សាកំព្យូទ័រ នៅមណ្ឌលទុំឌី ដល់កុមារីចំនួន៩៦នាក់ ក្នុងនោះមាន៧៩នាក់ជាកុមារីស្នាក់នៅក្នុងមណ្ឌល ៦នាក់ជានិស្សិតអាហារូបករណ៍សកលវិទ្យាល័យ និង ១១នាក់ទៀត ជាកុមារីមកពីសហគមន៍។<br><br>មានកុមារីចំនួន២៣នាក់ បានបញ្ចប់វគ្គសិក្សាកំព្យូទ័រដោយជោគជ័យ បានទទួលវិញ្ញាបនបត្រ។ ក្នុងនោះមាន៥នាក់បានរៀនចប់កម្មវិធី Adobe photoshop, ១២នាក់ចប់កម្មវិធី Excel និង PowerPoint និង៦នាក់ទៀតបានចប់កម្មវិធី Ms. Word។ |

| | | | |
|---|---|---|---|
| 3.2.2.9 | យើងនឹងឧបត្ថម្ភសម្ភារៈសិក្សាដល់កុមារីសិក្សាអប់រំនៅសហគមន៍ចំនួន៥៨នាក់ ក្នុងនោះ៤៣នាក់ជាកុមារីសល់ពីឆ្នាំ ២០១៩ និង ១៥នាក់ទៀត ជាកុមារីសិក្សាអប់រំនៅសហគមន៍ថ្មីក្នុងឆ្នាំ២០២០ ។ | 3.2.2.9 | មានកុមារីសិក្សាអប់រំនៅសហគមន៍ចំនួន៦៣នាក់បានទទួលការឧបត្ថម្ភពីអង្គការអោហ្វេស៊ីបកម្ពុជា ។ ក្នុងនោះកុមារីចំនួន១៩នាក់ ជាករណីសិក្សាអប់រំសហគមន៍ថ្មីក្នុងឆ្នាំ២០២០ ហើយ ៤៤នាក់ទៀត ជាកុមារីសល់ពីចុងខែធ្នូ ឆ្នាំ ២០១៩។ មានកុមារី២នាក់បានទទួលចូលមណ្ឌលវិញដោយស្ថានភាពហានិភ័យក្នុងគ្រួសារ ២នាក់បានប្តូរទៅហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈផ្នែកបដិសណ្ឋារកិច្ច និងអ៊ុតសក់ ហើយនិង៥នាក់ទៀតបានបោះបង់ការសិក្សាដោយមូលហេតុរៀបការ និងរកការងារធ្វើដើម្បីជួយគ្រួសារ។ មានយុវនារី និងកុមារីចំនួន៥៤នាក់កំពុងបន្តការសិក្សាអប់រំនៅសហគមន៍បន្តសំរាប់ឆ្នាំសិក្សា២០២០-២០២១។ |
| 3.2.2.10 | យើងនឹងឧបត្ថម្ភការរៀនបន្ថែម ដល់កុមារីសិក្សាអប់រំសហគមន៍រស់នៅជាមួយគ្រួសារនៅតាមសហគមន៍ចំនួន១១នាក់ ដែលកំពុងសិក្សាថ្នាក់ទី៩ចំនួន៧នាក់ និង ថ្នាក់ទី១២ចំនួន៤នាក់ ។ | 3.2.2.10 | យើងបានឧបត្ថម្ភការរៀនបន្ថែមប្រចាំខែ ដល់កុមារីសិក្សាអប់រំសហគមន៍ចំនួន១២នាក់ ដែលសិក្សាថ្នាក់ទី៩ចំនួន៨នាក់និងថ្នាក់ទី១២ចំនួន៤នាក់។ |
| 3.2.2.11 | យើងនឹងផ្តល់រង្វាន់លើកទឹកចិត្តដល់កុមារីសិក្សាអប់រំសហគមន៍ចំនួន១១នាក់ ដែលជាសិស្សពូកែប្រចាំថ្នាក់ពីលេខ១-៣ ចំនួន ៧នាក់ និងសិស្សទទទួលបាននិទ្ទេសC ចំនួន៤នាក់។ | 3.2.2.11 | យើងមិនបានអនុវត្តសកម្មភាពនេះទេដោយបញ្ហាថវិកា។ |
| 3.2.2.12 | យើងនឹងឧបត្ថម្ភ ការផ្ទេរឯកសារការសិក្សាដល់កុមារីសិក្សាអប់រំសហគមន៍ចំនួន១៥នាក់ សំរាប់ចូលរៀននៅសហគមន៍។ | 3.2.2.12 | យើបានឧបត្ថម្ភ ការផ្ទេរឯកសារការសិក្សាដល់កុមារីសិក្សាអប់រំសហគមន៍ចំនួន១៩នាក់ សំរាប់ការចូលរៀននៅមូលដ្ឋានក្នុងសហគមន៍។ |
| 3.2.2.13 | យើងនឹងឧបត្ថម្ភកង់ដល់កុមារីសិក្សាអប់រំសហគមន៍ចំនួន២០នាក់ សំរាប់ជាមធ្យោបាយធ្វើដំណើរ ទៅសាលារៀនប្រចាំថ្ងៃ។ | 3.2.2.13 | យើងបានឧបត្ថម្ភកង់ ដល់កុមារីសិក្សាអប់រំសហគមន៍ចំនួន១៧នាក់ សំរាប់ជាមធ្យោបាយធ្វើដំណើរទៅសាលារៀន ជាជំនួយពី88bikes និងកាកបាទក្រហមកម្ពុជា។ |

| | | | |
|---|---|---|---|
| 3.2.2.14 | យើងនឹងបញ្ជូនកុមារីនៅមណ្ឌលចំនួន១៥ នាក់ ត្រឡប់ទៅរស់នៅ ជាមួយគ្រួសារ នៅតាមសហគមន៍វិញ តាមរយៈការឧបត្ថម្ភការសិក្សាអប់រំសហគមន៍។ | 3.2.2.14 | យើងបានបញ្ជូនកុមារីចេញពីមណ្ឌលចំនួន១៩ នាក់ អោយត្រឡប់ទៅរស់នៅជាមួយគ្រួសារនៅតាមសហគមន៍វិញ ដើម្បីអោយពួកគាត់រស់នៅជួបជុំគ្រួសារ ហើយយើងបានឧបត្ថម្ភការសិក្សាអប់រំសហគមន៍ដល់ពួកគាត់។ យើងធ្វើការលើកកម្ពស់ការថែទាំកុមារនៅក្នុងគ្រួសារជាជាងអោយពួកគេរស់នៅក្នុងមណ្ឌល ព្រោះថាកុមារត្រូវការការលូតលាស់ល្អ នៅក្នុងបរិយាកាសគ្រួសារ។ |
| 3.2.2.15 | យើងនឹងមិនឧបត្ថម្ភ ថ្លៃជួលបន្ទប់ស្នាក់នៅប្រចាំខែដល់កុមារីសិក្សាអប់រំសហគមន៍ ដែលមានសាលានៅឆ្ងាយពីផ្ទះទេ ព្រោះថាពួកគាត់អាចយកលុយដែលនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានឧបត្ថម្ភជួលបន្ទប់បាន។ | 3.2.2.15 | យុវនារីសិក្សាអប់រំសហគមន៍ចំនួន១នាក់លេខកូដKC-0112 បានជួលបន្ទប់ស្នាក់នៅប្រចាំខែដោយប្រើលុយដែលនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានឧបត្ថម្ភ ព្រោះសាលានៅឆ្ងាយពីផ្ទះ ដែលនាងត្រូវធ្វើដំណើរឆ្លងទន្លេ២ដោយទូក និងចំណាយពេលជាច្រើនម៉ោង ដើម្បីមកសាលារៀន។ |
| 3.2.2.16 | យើងនឹងធ្វើការពិនិត្យតាមដានបន្ត ដោយការចុះជួបផ្ទាល់ និង តាមរយៈទូរស័ព្ទ ចំនួន ២៣២ដង ជាមួយកុមារីសិក្សាអប់រំសហគមន៍ ចំនួន៥៨នាក់ ដែលរស់នៅជាមួយគ្រួសារ។ | 3.2.2.16 | យើងបានពិនិត្យ និង តាមដានបន្តប្រចាំខែជាមួយកុមារីសិក្សាអប់រំសហគមន៍ចំនួន៦៣ នាក់ បានចំនួន១៣១ដង ទាំងការចុះជួបផ្ទាល់ និង តាមរយៈទូរស័ព្ទ ដើម្បីពិនិត្យតាមដានការវិវឌ្ឍន៍នៃការសិក្សា បញ្ហាប្រឈម បញ្ហាសុខភាព និង ស្ថានភាពនៃការរស់នៅរបស់ពួកគេ។ ការតាមដានបន្តចំនួន១១៦ដងបានធ្វើឡើងតាមរយៈទូរស័ព្ទ និង១៥ដងទៀតបានចុះផ្ទាល់។ |
| 3.2.2.17 | យើងនឹងឧបត្ថម្ភដល់និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១៦នាក់ ដោយរាប់បញ្ចូលទាំងនិស្សិត១នាក់ដែលកំពុងសិក្សានាយទាហ៊ានសកម្មនៅសកលវិទ្យាល័យក្រសួងការពារជាតិ។ ក្នុងនោះ៥នាក់ (នឹងចូលរៀននៅខែវិច្ឆិកា) ១នាក់ចេញពីមណ្ឌល និង៤នាក់ទៀតប្រឡងចេញពីអប់រំសហគមន៍) ជានិស្សិតអាហារូបករណ៍ថ្មីសំ | 3.2.2.17 | យើងបានឧបត្ថម្ភដល់និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១១នាក់ (ដោយរាប់បញ្ចូលទាំងនិស្សិត១នាក់កំពុងសិក្សានៅសាលានាយទាហ៊ានសកម្មនៃសកលវិទ្យាល័យក្រសួងការពារជាតិ) ដែលសិក្សានៅតាមបណ្ដាសកលវិទ្យាល័យនានា តាមមុខជំនាញផ្សេង ៗ ដូចជា នាយទាហានសកម្ម ធុរកិច្ចនិងរដ្ឋបាល អក្សរសាស្ត្រខ្មែរ អក្សរសាស្ត្រអង់គ្លេស ទេសចរណ៍ និងបដិសណ្ឋារកិច្ច នីតិសាស្ត្រនិងសេដ្ឋកិច្ច ទី |

| | | | |
|---|---|---|---|
| | រាប់ឆ្នាំ២០២០ និង ១១នាក់ទៀត ជានិស្សិតពីឆ្នាំ២០១៩។ និស្សិតចំនួន១៥នាក់នឹងទទួលការឧបត្ថម្ភថ្លៃសាលា។ | | ផ្សារនិងទំនាក់ទំនង ធនាគារនិងហិរញ្ញវត្ថុ និង រដ្ឋបាលសាធារណៈ។ ក្នុងនោះយើងបានឧបត្ថម្ភថ្លៃសាលាដល់និស្សិតចំនួន១០នាក់។<br><br>មាននិស្សិត២នាក់បានចេញពីកម្មវិធី ដោយ១នាក់បានបោះបង់ការសិក្សានៅឆមាសទី១ឆ្នាំទី៣ និង១នាក់ទៀតយើងបានបណ្តេញចេញពីកម្មវិធីអាហារូបករណ៍នៅឆមាសទី១ឆ្នាំទី១ ដោយគាត់បានប្រព្រឹត្តិខុសក្រមសីលធម៌នៃកិច្ចសន្យាអាហារូបករណ៍ធ្ងន់ធ្ងរជាច្រើនលើកច្រើនសារដដែលៗមិនព្រមកែរប្រែ។<br><br>មាននិស្សិតតែ១១នាក់ក្នុងឆ្នាំ២០២០នេះ មិនបាន១៦នាក់ តាមផែនការរំពឹងទុករបស់យើង ថានឹងមាននិស្សិតអាហារូបណ៍ចំនួន៥ទៀត ក្នុងឆ្នាំ២០២០ ដោយ១នាក់នឹងត្រូវប្រឡងចេញពីមណ្ឌល និង៤នាក់ទៀតនឹងត្រូវប្រឡងចេញពីការអប់រំសហគមន៍ តែដោយសារបញ្ហាការផ្ទុះនៃការរាតត្បាតមេរោគកូវីដ-១៩ ក្រសួងអប់រំយុវជន និងកីឡា បានបិទសាលារៀនទូទាំងប្រទេស និងលើកការប្រឡងមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេសដោយមិនកំណត់ ដើម្បីការ ពារការឆ្លងមេរោគកូវីដ-១៩។ |
| 3.2.2.18 | យើងនឹងឧបត្ថម្ភថ្លៃសាលា និងការរស់នៅប្រចាំខែដល់និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន១៥នាក់ ។ | 3.2.2.18 | យើងបានឧបត្ថម្ភថ្លៃសាលា និងការរស់នៅប្រចាំខែដល់និស្សិតអាហារូបករណ៍ចំនួន១០នាក់។ |
| 3.2.2.19 | យើងនឹងឧបត្ថម្ភកំព្យូទ័រយួរដៃ ដល់និស្សិតអាហារូបករណ៍ថ្មីចំនួន៥នាក់ ដោយក្នុង១នាក់ ១គ្រឿង សំរាប់ជាជំនួយដល់ការសិក្សារបស់ពួកគាត់។ | 3.2.2.19 | យើងមិនបានឧបត្ថម្ភកំព្យូទ័រយួរដៃដល់និស្សិតថ្មីចំនួន៥នាក់ទេ ដោយពួកគាត់មិនទាន់បានចូលរៀននៅសកលវិទ្យាល័យនៅឡើយទេ ព្រោះក្រសួងអប់រំយុវជន និងកីឡាបានពន្យាពេលនៃការប្រឡងមធ្យមសិក្សាទុតិយភូមិ នៅក្នុងឆ្នាំ២០២០ដោយមិនកំណត់។ |

| | | | |
|---|---|---|---|
| 3.2.2.20 | យើងនឹងឧបត្ថម្ភការសិក្សាភាសាអង់គ្លេសដល់និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៧នាក់ ។ | 3.2.2.20 | យើងបានឧបត្ថម្ភការសិក្សាភាសាអង់គ្លេសក្រៅម៉ោងវគ្គខ្លីនៅតាមសាលាឯកជន ដល់និស្សិតអាហារូបករណ៍ចំនួន៧នាក់ ។ |
| 3.2.2.21 | យើងនឹងឧបត្ថម្ភនិស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៥នាក់ អោយសិក្សាកំព្យូទ័រក្រៅម៉ោងវគ្គខ្លីនៅសាលាឯកជន។ | 3.2.2.21 | យើងបានឧបត្ថម្ភការសិក្សាកំព្យូទ័រក្រៅម៉ោងវគ្គខ្លីនៅសាលាឯកជន ដល់និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៧នាក់ ។ |
| 3.2.2.22 | យើងនឹងឧបត្ថម្ភកញ្ចប់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ដល់និស្សិតអាហារូបករណ៍សកលវិទ្យាល័យចំនួន៥នាក់។ | 3.2.2.22 | យើងមិនទាន់បានឧបត្ថម្ភកញ្ចប់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ដល់និស្សិតអាហារូបករណ៍សកលវិទ្យាល័យថ្មីទេ ព្រោះត្រូវលើកពេលប្រឡងមធ្យមសិក្សាទុតិយភូមិដោយសារការរាតត្បាតមេរោគកូវីដ-១៩។ |
| 3.2.2.23 | យើងនឹងរៀបចំការប្រជុំពិនិត្យតាមដានចំនួន១២ដង ជាមួយនិស្សិតអាហារូបករណ៍សកលវិទ្យាល័យទាំងអស់នៅការិល័យអង្គការអាហ្វេស៊ីបកម្ពុជា។ | 3.2.2.23 | យើងបានរៀបចំការប្រជុំពិនិត្យតាមដានប្រចាំខែ ជាមួយនិស្សិតអាហារូបករណ៍សកលវិទ្យាល័យ ទាំងអស់ បានចំនួន១២ដង នៅការិល័យអាហ្វេស៊ីបកម្ពុជា និងបានធ្វើការតាមដានបន្តចំនួន៩៨ដងដល់និស្សិតចំនួន១១នាក់។ |
| 3.2.2.24 | យើងនឹងឧបត្ថម្ភការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅដល់យុវនារីចំនួន៧នាក់ តាមបំណងប្រាថ្នា និងឆន្ទៈរបស់ពួកគាត់។ | 3.2.2.24 | មានយុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅចំនួន៦នាក់ ដោយយើងបានឧបត្ថម្ភតម្លៃហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈនៅខាងក្រៅចំនួន៤នាក់ ហើយ២នាក់ទៀតយើងមិនបានបង់ថ្លៃទេ។ ក្នុងនោះ៤នាក់ បានហ្វឹកហ្វឺនជំនាញអ៊ុតសក់នៅខេត្តសៀមរាប និង២នាក់ទៀតបានហ្វឹកហ្វឺនជំនាញចុងភៅ និងភេជ្ជៈនៅភ្នំពេញ ។ យុវនារីសិក្សាជំនាញខាងក្រៅ២នាក់សល់ពីឆ្នាំ២០១៩ ហើយយុវនារី៤នាក់ទៀត ជាយុវនារីចូលហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅថ្មី ក្នុងឆ្នាំ២០២០។ មានយុវនារីចំនួន២នាក់ បានបញ្ចប់ការហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅដោយជោគជ័យ និងយុវនារី៤នាក់ទៀតកំពុងបន្តការសិក្សាជំនាញខាក្រៅ។<br>យើងបានធ្វើការតាមដានបន្តសួរសុខទុក្ខដល់យុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅចំនួន |

| | | | |
|---|---|---|---|
| | | | ៥នាក់បានចំនួន៤០ដងអំពីការសិក្សារៀនសូត្រ សុខភាព និងការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ |
| 3.2.2.25 | យើងនឹងឧបត្ថម្ភការរស់នៅប្រចាំខែដល់យុវនារីសិក្សាជំនាញវិជ្ជាជីវៈខាងក្រៅចំនួន៧នាក់ ។ | 3.2.2.25 | យើងបានឧបត្ថម្ភការរស់នៅប្រចាំខែដល់យុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅចំនួន៦នាក់ ។ |
| 3.2.2.26 | យើងនឹងធ្វើបទបង្ហាញ អំពីការតម្រង់ទិស ចំនួន៧ដង ដល់យុវនារី និង កុមារីចូលថ្មីដែលមានបំណងចង់សិក្សាជំនាញវិជ្ជាជីវៈខាងក្រៅ។ | 3.2.2.26 | យើងបានធ្វើបទបង្ហាញ អំពីការតម្រង់ទិស ចំនួន៤ដង ដល់យុវនារីសិក្សាជំនាញវិជ្ជាជីវៈខាងក្រៅថ្មីចំនួន៤នាក់ ដើម្បីជួយជាជំនួយដល់ការសំរេចចិត្ត តាមឆន្ទៈរបស់ពួកគាត់ ក្នុងការជ្រើសរើសជំនាញអោយបានត្រឹមត្រូវ។ |
| **៣.២.៣ កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច** | | | |
| 3.2.3.1 | យើងនឹងបន្តកិច្ចសន្យាការងារជាមួយបុគ្គលិកចំនួន២នាក់ អោយបំរើការនៅកម្មវិធីលើកម្ពស់សេដ្ឋកិច្ច។ ១នាក់ជាប្រធានកម្មវិធីប្រចាំនៅរាជធានីភ្នំពេញ និង១នាក់ទៀតជាបុគ្គលិកប្រចាំនៅខេត្តសៀមរាប។ | 3.2.3.1 | យើងបានបន្តកិច្ចសន្យាការងារជាមួយបុគ្គលិកចំនួន២នាក់ អោយបំរើការនៅកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច។ ១នាក់ ជាប្រធានកម្មវិធី ប្រចាំនៅមណ្ឌលទុំឌីនៅភ្នំពេញ មានតួនាទី២ជាប្រធានកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច និងជាបុគ្គលិកកម្មវិធីចិត្តសាស្ត្រ និង១នាក់ទៀតជាបុគ្គលិកបំរើការប្រចាំនៅខេត្តសៀមរាប ដើម្បីជួយសំរួលដល់ការងារសមាហរណកម្ម យុវនារីហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈខាងក្រៅ ការតាមដានបន្ត ការចុះទៅទទួលយកកុមារីរងគ្រោះចូលមណ្ឌលទុំឌី និងទំនាក់ទំនងជាមួយអង្គការ និងស្ថាប័នដៃគូរនៅក្នុងខេត្តសៀមរាប និងតាមបណ្តាខេត្តជាប់ខេត្តសៀរាប។ |
| 3.2.3.2 | យើងនឹងជូនយុវនារី និងកុមារីចំនួន៨០នាក់ដែលស្នាក់នៅទទួលការថែទាំ នៅមណ្ឌលទុំឌី ទៅលេងគ្រួសារចំនួន១២០ដង ។ ការទៅលេងគ្រួសាររបស់យុវនារី និងកុមារីភាគច្រើន គឺនៅរដូវចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌ ។ | 3.2.3.2 | យើងបានរៀបចំអោយ យុវនារី និង កុមារី ចំនួន២៧នាក់ បានទៅលេងគ្រួសារ បានចំនួន៣១ដង។ ក្នុងនោះបុគ្គលិកបាននាំយុវនារី និង កុមារីទៅលេងគ្រួសាររបស់ពួកគាត់នៅតាមសហគមន៍បានចំនួន២០ដង និង គ្រួសារសាច់ញាតិរបស់ពួកគាត់បានមកលេងពួកគាត់នៅ |

| | | | |
|---|---|---|---|
| | | | មណ្ឌលចំនួន១១ដង។ ដោយសារបញ្ហាការផ្ទុះឡើងនូវមេរោគកូវីដ-១៩ និងរដ្ឋាភិបាលបានលើកថ្ងៃនៃការប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ទើបចំនួននៃការទៅលេងគ្រួសាររបស់យុវនារី និងកុមារីមានចំនួនតិចជាងផែនការរំពឹងទុករបស់យើង។ |
| 3.2.3.3 | យើងនឹងសមាហរណកម្មយុវនារីចំនួន៧នាក់ ដែលបានបញ្ចប់ការហ្វឹកហ្វឺននូវមុខជំនាញវិជ្ជាជីវៈដែលខ្លួនបានជ្រើសរើសដោយជោគជ័យ ដោយក្នុងនោះមានចំនួន៤នាក់នឹងឧបត្ថម្ភការបង្កើតមុខរបរខ្នាតតូច និង៣នាក់ទៀតនឹងឧបត្ថម្ភការងារ។ | 3.2.3.3 | យើងបានបញ្ជូន និងសមាហរណកម្ម យុវនារី និងកុមារីចំនួន២៦នាក់ ដែលបានស្តារនីតិសម្បទា ជាសះស្បើយ សុខភាពផ្លូវចិត្ត និង របួសផ្លូវកាយ បានបញ្ចប់ការហ្វឹកហ្វឺនមុខជំនាញវិជ្ជាជីវៈខាងក្រៅដោយជោគជ័យ ត្រឡប់ទៅកាន់សហគមន៍វិញ ដូចខាងក្រោមៈ<br>- ២នាក់បានសមាហរណកម្មការងារ(ក្រៅ)<br>- ២នាក់បានសមាហរណកម្មទៅគ្រួសារ<br>- ៣នាក់ទៅហ្វឹកហ្វឺនជំនាញវិជ្ជាជីវៈក្រៅ<br>- ១៩នាក់បានបញ្ជូនសិក្សាអប់រំសហគមន៍ |
| 3.2.3.4 | យើងនឹងធ្វើការតាមដានបន្ត យុវនារីចំនួន ១១៨នាក់ ដែលបានធ្វើសមាហរណកម្មដោយការឧបត្ថម្ភមុខរបរខ្នាតតូច និងការងារ ដោយចុះផ្ទាល់ និងតាមរយៈទូរស័ព្ទ ចំនួន៣០០ដង ។ | 3.2.3.4 | យើងបានធ្វើការតាមដានបន្ត ដោយផ្ទាល់ និងតាមទូរស័ព្ទបានចំនួន១០៦ដង ជាមួយយុវនារីដែលបានធ្វើសមាហរណកម្មដោយការឧបត្ថម្ភមុខរបរខ្នាតតូច និងការងារចំនួន៣៧នាក់ ។ ការតាមដានបន្តក្រោយសមាហរណកម្មបានតិចជាងផែនការរំពឹងទុករបស់យើងដោយសារបញ្ហាពេលវេលា និងធនធានមនុស្ស។ |
| 3.2.3.5 | យើងនឹងឧបត្ថម្ភជំនួយគ្រួសារដល់គ្រួសារយុវនារី និង កុមារីចំនួន៦គ្រួសារ ដោយក្នុងនោះមាន៣គ្រួសារជាគ្រួសារកុមារីស្នាក់នៅក្នុងមណ្ឌល និង៣គ្រួសារទៀតជាករណីសិក្សាអប់រំសហគមន៍ តាមស្ថានភាពជាក់ស្តែងរបស់គ្រួសារនីមួយៗ ។ | 3.2.3.5 | យើងបានឧបត្ថម្ភជំនួយគ្រួសារដល់គ្រួសារកុមារីអប់រំសហគមន៍២នាក់ដែលមានលេខកូដ SR-0555 និងSR-0556(ជាបងប្អូនបង្កើត) ចំនួន១គ្រួសារ តាមតម្រូវការជាក់ស្តែង ដើម្បីទិញម៉ូតូជំនុំ១គ្រឿងជាមធ្យោបាយបង្កើតមុខរបរប្រចាំថ្ងៃ។ |
| 3.2.3.6 | យើងនឹងឧបត្ថម្ភជំនួយបន្ថែមដល់យុវនារី និងកុមារីបានធ្វើសមាហរណកម្មរួចហើយ ចំនួន១៥នាក់ តាមតម្រូវការជាក់ស្តែង។ | 3.2.3.6 | យើងបានឧបត្ថម្ភយុវនារី ធ្វើសមាហរណកម្មរួចហើយ ចំនួន៥នាក់ ។ ក្នុងនោះមាន២នាក់ បានទទួលការឧបត្ថម្ភថវិកាសំរាប់ទិញអាហារ ១ |

| | |
|---|---|
| | នាក់ឧបត្ថម្ភការព្យាបាលជំងឺ និង២នាក់ទៀតបានទទួលការឧបត្ថម្ភសំរាប់អាពាហ៍ពិពាហ៍។ |
| **៣.២.៤ កម្មវិធីក្រុមគោលដៅ**<br><br>3.2.4.1 យើងនឹងបន្តកិច្ចសន្យាការងារជាមួយបុគ្គលិក៣នាក់ អោយបំរើការនៅកម្មវិធីក្រុមគោលដៅនៅរាជធានីភ្នំពេញ។ | 3.2.4.1 យើងបានបន្តកិច្ចសន្យាការងារ ជាមួយបុគ្គលិក ៣នាក់ ដែលកំពុងបំរើការនៅកម្មវិធីក្រុមគោលដៅ ដើម្បីបន្តការងារនៅរាជធានីភ្នំពេញ។<br><br>**កំណត់ចំណាំ:** ដោយបញ្ហាផ្ទុះឡើងនូវមេរោគកូវីដ-១៩ បានធ្វើអោយប៉ះពាល់ដល់ថវិកា យើងបានបិទកម្មវិធីក្រុមគោលដៅនេះនៅដើមខែមិនា២០២០មកម្លេះ ។ |
| 3.2.4.2 យើងនឹងជ្រើសរើសក្រុមមិត្តអប់រំមិត្តចំនួន១នាក់ ដើម្បីជួយសម្រួលការងារ កម្មវិធីក្រុមគោលដៅ។ | 3.2.4.2 យើងបានជួលក្រុមមិត្តអប់រំមិត្តចំនួន១នាក់អោយជួយសម្រួលការងារតាមទីតាំងរបស់កម្មវិធីក្រុមគោលដៅ ប្រចាំនៅរាជធានីភ្នំពេញ។ |
| 3.2.4.3 យើងនឹងចុះផ្តល់ការអប់រំ ដល់ស្រ្តីបំរើសេវាកំសាន្តសប្បាយចំនួន២,៥០០នាក់ នៅតាមទីតាំងបំរើសេវាកំសាន្តសប្បាយចំនួន២៥០ទីតាំង។ | 3.2.4.3 យើងបានចុះអប់រំដល់ស្រ្តីបំរើសេវាកំសាន្តសប្បាយ បានចំនួន៣,៧៨៨នាក់ នៅតាមបណ្តាទីតាំងបំរើសេវាកំសាន្តសប្បាផ្សេង ៗ ចំនួន៣២៣ទីតាំង នៅរាជធានីភ្នំពេញ ។ |
| 3.2.4.4 បុគ្គលិក និង សមាជិកក្រុមមិត្តអប់រំមិត្តយើងនឹងចុះផ្តល់ស្រោមអនាម័យ ចំនួន១៣ប្រអប់ធំ និង សម្ភារៈអនាម័យផ្សេងៗ ដល់ស្រ្តីបំរើសេវាកំសាន្តសប្បាយ នៅតាមទីតាំងនៅរាជធានីភ្នំពេញ ។ | 3.2.4.4 យើងបានចុះអប់រំ និង ចែកស្រោមអនាម័យចំនួន៣ប្រអប់ធំ (៧,៩១៤ស្រោម) សាប៊ូដុំចំនួន៣៥៩ដុំ ច្រាស និងថ្នាំដុះធ្មេញចំនួន១២៣ដើម ដល់ស្រ្តីបំរើសេវាកំសាន្តសប្បាយនៅតាមទីតាំងភ្លើងពណ៌ (ទីតាំងកំសាន្តសប្បាយ)។ |
| 3.2.4.5 យើងនឹងបញ្ជូនស្រ្តីបំរើសេវាកំសាន្តសប្បាយចំនួន១៥០នាក់ ដែលមានបញ្ហាសុខភាពទៅកាន់មណ្ឌលសុខភាពដៃគូរ ដើម្បីទទួលបានការថែទាំសុខភាព តាមតម្រូវការជាក់ស្តែង។ | 3.2.4.5 យើងបានបញ្ជូនស្រ្តីបំរើសេវាកំសាន្តសប្បាយចំនួន១០៧នាក់ ទៅកាន់មណ្ឌលសុខភាពដើម្បីទទួលការពិនិត្យព្យាបាល និង ថែទាំសុខភាពចំនួន១៣៩ដង តាមតម្រូវការជាក់ស្តែង។ |

| | | | |
|---|---|---|---|
| 3.2.4.6 | យើងនឹងបញ្ចុះបញ្ចូលស្ត្រីបំរើសេវាកំសាន្តសប្បាយចំនួន១០នាក់ (២នាក់នឹងជួយឧបត្ថម្ភដោយអង្គការអាហ្វេស៊ីបកម្ពុជាក្នុង១នាក់ចំនួន៣០០ដុល្លារអាមេរិក)អោយបោះបង់មុខរបររកស៊ីផ្លូវភេទ ហើយយើងនឹងផ្តល់ជំរើសអោយពួកគាត់ តាមរយៈការជ្រើសយកការសិក្សាជំនាញវិជ្ជាជីវៈ ឬ ការបង្កើតមុខរបរចិញ្ចឹមជីវិត ជាមួយចំណេះជំនាញដែលពួកគាត់ចេះស្រាប់។ | 3.2.4.6 | យើងបានបញ្ចុះបញ្ចូលស្ត្រីបំរើសេវាកំសាន្តសប្បាយបានចំនួន១នាក់ អោយបោះបង់មុខរបររកស៊ីផ្លូវភេទ បង្កើតមុខរបរថ្មីចិញ្ចឹមជីវិត ដោយការប្រើប្រាស់ចំណេះដែលគាត់មានស្រាប់ ។ |
| 3.2.4.7 | យើងនឹងកសាងទំនាកទំនងល្អ និង ការបញ្ច្រៀបការយល់ដឹងអំពីសកម្មភាពការងារអង្គការ អាហ្វេស៊ីប កម្ពុជា ដល់បណ្តាអ្នកឧបត្ថម្ភ អ្នកគាំទ្រ អង្គការ ស្ថាប័នជាដៃគូរ។ | 3.2.4.7 | យើងបានរៀបចំជូនភ្ញៀវចំនួន៥នាក់មកពីក្រុមហ៊ុនកូនីកាមីណុលតាប្រទេសអូស្ត្រាលី ចុះធ្វើទស្សនកិច្ចសិក្សាស្វែងយល់ អំពីសកម្មភាពការងាររបស់កម្មវិធីក្រុមគោលដៅចំនួន១ដងនៅតាមបណ្តាទីតាំងភ្លើងពណ៌នានានៅរាជធានីភ្នំពេញ។ |

## IV. របាយការណ៍ ហិរញ្ញវត្ថុ

ជាទូទៅ យើងធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់យើង ដោយការជួលក្រុមហ៊ុនសវនកម្មឯកជននៅក្នុងរង្វង់ខែកក្កដា ជារៀងរាល់ឆ្នាំ ហើយក្រុមហ៊ុនសវនកម្មត្រូវការពេលវេលាប្រហែល៣-៤ សប្តាហ៍ដើម្បីបញ្ចប់ការធ្វើសវនកម្ម និងផ្តល់របាយការណ៍អោយយើង។ ដើម្បីអោយមានគណនេយ្យភាព និងតម្លាភាព យើងតែងតែធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មរបស់យើងជូនម្ចាស់ជំនួយរបស់យើង និងប្រកាសនៅលើគេហទំព័ររបស់អង្គការអាហ្វេស៊ីប កម្ពុជា។ ប្រសិនបើ លោក លោកស្រី នាងកញ្ញា ត្រូវការមើលរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុរបស់យើងកាលពីឆ្នាំមុន ៗ សូមចូលទៅកាន់គេហទំព័ររបស់យើង afesip.org ។